សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

ការរៀបចំ ការអនុវត្ត និង ការត្រួតពិនិត្យ ថវិកា ឃុំ សង្កាត់

ស្រាវជ្រាវពីថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

សាវជ្រាវឡើងដោយ

និស្សិតឈ្មោះ កញ្ញា **ចាន ចិន្ត្រា**

កញ្ញា **យ័ញ្ញ មុន្នីរតនា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ខេង សុខ**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរបាយការណ៍ ២០២៤

មាតិកា

ទំព័រ

សេចក្តីថ្លែងអំណរគុណ iv

អារម្ភកថា vi

សេចក្តីផ្តើម ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ..... ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ១

៣. គោលបំណងនៃការស្រាវជ្រាវ..... ២

៤. ដែនកំណត់នៃការស្រាវជ្រាវ ២

៥. វិធីសាស្ត្រស្រាវជ្រាវ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ..... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..... ៣

ជំពូកទី១

សញ្ញាណទូទៅនៃចំណាត់ថ្នាក់ថវិការដ្ឋ

១.១.ចំណាត់ថ្នាក់ថវិកាថ្នាក់ជាតិ..... ៤

១.១.១.ថវិកាទូទៅ..... ៤

១.១.២.ថវិកាឧបសម្ព័ន្ធ..... ៦

១.១.៣.ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៦

១.១.៤.គណនីពិសេសរតនាគារ..... ៧

១.២.ចំណាត់ថ្នាក់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៧

១.២.១.ប្រវត្តិ និង ការវិវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ..... ៨

១.២.២.ថវិការដ្ឋបាលរាជធានី ខេត្ត ៩

១.២.៣.ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ..... ១០

១.២.៤.ថវិការដ្ឋបាល ឃុំ សង្កាត់ ១៤

ជំពូកទី២

ការរៀបចំ ការអនុម័ត និង ការអនុវត្តថវិការដ្ឋបាលឃុំ សង្កាត់

២.១ ការរៀបចំ និងអនុម័តថវិការឃុំ សង្កាត់..... ១៦

២.១.១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា..... ១៨

២.១.២ ការរៀបចំកញ្ចប់ថវិកា ១៩

២.១.៣ ការអនុម័តថវិកា ២១

២.២ បន្ទុក និងធនធាន ហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់..... ២១

២.២.១ បន្ទុក និងធនធានហិរញ្ញវត្ថុរដ្ឋបាល ឃុំ ២២

២.២.២ បន្ទុក និងធនធានហិរញ្ញវត្ថុរដ្ឋបាល សង្កាត់ ២៥

២.៣ ការអនុវត្តថវិកាឃុំ សង្កាត់..... ២៦

២.៣.១ កិច្ចប្រតិបត្តិការចំណូល និងចំណាយ..... ២៦

២.៣.២. ការគ្រប់គ្រងថវិការដ្ឋបាលឃុំ សង្កាត់..... ២៩

ជំពូកទី៣

ការត្រួតពិនិត្យលើការអនុវត្តថវិកាឃុំ សង្កាត់

៣.១. ការត្រួតពិនិត្យលើអាណាប័កដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ... ៣០

៣.១.១ ការត្រួតពិនិត្យវិភាដោយសភា ៣០

៣.១.២.ការត្រួតពិនិត្យពេលកំពុងអនុវត្ត..... ៣០

៣.១.៣.ការត្រួតពិនិត្យពេលក្រោយអនុវត្ត ៣១

៣.២.ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុដោយសវនកម្មផ្ទៃក្នុង ៣១

សេចក្តីសន្និដ្ឋាន..... ៣៤

អនុសាសន៍..... ៤១

ឯកសារយោង ៥0

សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ចាន ចិត្រ្តា** និង **យ័ញ្ញ មុន្នីរតនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រវដ្ឋបាលសាធារណៈ ជំនាន់ទី១៧នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពថ្លែងអំណគុណនូវការដឹងគុណ និង កតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោកអ្នកមានគុណទាំងពីរគឺ **លោកឪពុក ឥត ហាន** និង **អ្នកម្តាយ ឆុច ស៊ីណា** និង**លោកឪពុក យ័ញ្ញ ឡឹក** និង**អ្នកម្តាយ ហង្ស ចាន់ធី** ដែលកន្លងមកបានចិញ្ចឹមបីបាច់ថែរក្សាកូនផ្តល់ភាពកក់ក្តៅ និងការស្រលាញ់ថ្នាក់ថ្នមយ៉ាងល្អហើយតែងតែជម្រុញ លើកទឹកចិត្តកូនឲ្យខិតខំសិក្សារៀនសូត្រ ទោះបីកាលៈទេសៈខ្លះលោកទាំងពីរមានការលំបាកយ៉ាងណាក៏ដោយក៏ នៅតែព្យាយាមឲ្យកូនបានសិក្សារៀនសូត្រខ្ពង់ខ្ពស់។ មិនតែប៉ុណ្ណោះលោកអ្នកមានគុណទាំងពីរតែងតែប្រៀនប្រដៅ កូនឲ្យធ្វើតែអំពើល្អ មានក្រមសីលធម៌ល្អ អត់ធ្មត់តស៊ូជំនះរាល់ការលំបាកក្នុងជីវិត និងបញ្ហាទាំងឡាយដោយឈរលើសច្ចៈធម៌ គុណធម៌ជានិច្ច អប់រំកូនឲ្យក្លាយជាពលរដ្ឋល្អដែលសង្គមត្រូវការក៏ដូចជាផ្នែកមួយក្នុងការចូលរួមជួយ អភិវឌ្ឍសង្គមជាតិឲ្យមានវឌ្ឍនភាពផងដែរ។

សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ និង សហការីនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខិតដឹកនាំគ្រប់គ្រងសាលាប្រកបដោយការយកចិត្តទុកដាក់ និងខិតខំបង្ហាត់បង្រៀន ពង្រឹងការសិក្សារបស់និស្សិតគ្រប់រូបឱ្យមានសមត្ថភាព ចំណេះដឹង ដើម្បីអាចប្រកួតប្រជែងលើឆាកអន្តរជាតិលើកស្ទួយមុខមាត់ប្រទេសជាតិលើឆាកអន្តរជាតិផងដែរ។

បណ្ឌិត **ឆេង សុខ** ជាសាស្ត្រាចារ្យបំពេញវេលាការណ៍នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃរួមទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងគោលបំណង ណែនាំដល់យើងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "ការរៀបចំ ការអនុវត្ត និង ការត្រួតពិនិត្យថវិកា ឃុំ សង្កាត់" ហើយបានផ្តល់ការយកចិត្តទុកដាក់ខ្នះខ្នែងក្នុងការដឹកនាំ ផ្តល់ជាគំនិតយោបល់ល្អៗជាច្រើនរហូតចងក្រងសារណា បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។ មិនតែប៉ុណ្ណោះលោកគ្រូ សាស្ត្រាចារ្យតែងតែខិតខំបង្រៀនប្រៀនប្រដៅអប់រំ ដល់នាងខ្ញុំទាំងពីរនាក់ក៏ដូចជានិស្សិតដទៃទៀតឱ្យមានក្រមសីលធម៌ល្អ មានគុណធម៌ និងមានចំណេះដឹង ដើម្បីជាប្រយោជន៍ដល់សង្គមគ្រួសាររួមទាំងសង្គមជាតិ។

ជាចុងក្រោយនាងខ្ញុំទាំងពីរនាក់ **ចាន ចិត្រ្តា** និង **យ័ញ្ញ មុន្នីរតនា** សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកជួយថែ រក្សាអ្នកមានគុណគ្រប់រូបឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពុលៈ កុំបីឃ្លៀងឃ្លៀតឡើយ សូមអរគុណ។

អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំមកនេះ នាងខ្ញុំទទួលបានចំណេះដឹង និងពុទ្ធិជាច្រើន ទាំងបច្ចេកទេសក្នុងការរៀនសូត្រ ទ្រឹស្តី ការអនុវត្តជាក់ស្តែងមួយចំនួន ដែលពាក់ព័ន្ធនឹងជំនាញលើវិស័យសាធារណៈ និងច្បាប់ នៅក្នុងប្រទេសកម្ពុជា ជាពិសេសពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ការដឹកនាំ ការបម្រើសេវាសាធារណៈពិសេស ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាដើម ព្រមទាំងបានឈ្វេងយល់ខ្លះៗអំពីបរិបទច្បាប់ផ្សេងទៀតផងដែរ ដែលបានសិក្សានៅមហាវិទ្យាល័យរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហេតុនេះហើយទើបនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកការសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈរបស់យើងខ្ញុំ។

នាងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានជ្រើសរើសយកប្រធានបទស្តីពី ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកា ឃុំ សង្កាត់ មកស្រាវជ្រាវសរសេរជាសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ សារណានេះពិតជា មានតម្លៃ និងសារៈសំខាន់ណាស់សម្រាប់ឲ្យនាងខ្ញុំបានបញ្ចេញនូវសមត្ថភាព និងចំណេះដឹង ដែលទទួលបានពីការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងទៅនេះ បើទោះបីជាការសរសេរសារណានេះជាលើកដំបូង ហើយក៏ជាបទពិសោធន៍ថ្មីសម្រាប់យើងទាំងពីរនាក់ក្តី ប៉ុន្តែពួកយើងនឹងព្យាយាមខិតខំឲ្យអស់ពីសមត្ថភាពទាំងកម្លាំងកាយចិត្ត ដើម្បីឲ្យការសរសេរសារណានេះដំណើរការទៅដោយរលូន និងសម្រេចទទួលបាននូវភាពជោគជ័យ។ ប្រធានបទ៖ **ការរៀបចំ ការអនុវត្ត និង ការត្រួតពិនិត្យថវិកា ឃុំ សង្កាត់**

ត្រូវបានតាក់តែងឡើងក្នុងគោលបំណងចង់ឲ្យមិត្តនិស្សិតគ្រប់រូប ព្រមទាំងអ្នកស្រាវជ្រាវផ្សេងៗ និងប្អូនៗនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់បន្ត ក៏ដូចជា គ្រឹះមួយសម្រាប់ប្អូនៗដែលមានបំណងធ្វើបច្ចុប្បន្នភ្លៀមប្រឡង ឬសិក្សាស្រាវជ្រាវបន្ថែមឲ្យបានល្អប្រសើរជាងនេះ។ មិនតែប៉ុណ្ណោះក៏ជាទុនមួយក្នុងការសិក្សាដើម្បីជួយពង្រីក និងពង្រឹងចំណេះដឹង ទៅលើវិស័យសាធារណៈ ព្រមទាំងបានយល់ដឹងពីសន្ទុះរីកចម្រើននៃសេវាសាធារណៈនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ដោយសារតែពេលវេលានៃការស្រាវជ្រាវ និងការសរសេរសារណានេះមានការកំណត់គួបផ្សំនឹងកត្តាសមត្ថភាព បទពិសោធន៍ នាងខ្ញុំជឿជាក់ថាមានកំហុសដោយអចេតនា លើការប្រើប្រាស់ពាក្យពេចន៍ វេយ្យាករណ៍ អក្ខរាវិរុទ្ធ ឃ្លាឃ្លោង ល្បះ ខ្លឹមសារ នឹងប្រាកដជាមានកន្លែងចន្លោះខ្វះខាតក៏ដូចជានឹងមានការភ្លាំងភ្លាត់ជាក់ជាមិនខាន។ អាស្រ័យហេតុនេះ នាងខ្ញុំសូមអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងដោយប្រការណាមួយដែលកើតឡើងដោយអចេតនា នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ នាងខ្ញុំនឹងរង់ចាំទទួលជានិច្ចនូវរាល់មតិ ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលម្អកិច្ចការស្រាវជ្រាវនេះអោយបានកាន់តែល្អប្រសើរ សម្រាប់ជាប្រយោជន៍ដល់មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវបន្តលើសេវាសាធារណៈនៅកម្ពុជា។

សេចក្តីផ្តើម

សេចក្តីផ្តើម

១.ចំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាបានបង្កើត **ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ** ដំបូងឡើងក្នុងពេលដែលយើងបានស្តារឡើងវិញនូវលិទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីយើងបានអនុវត្តតាមលិទ្ធិសង្គមនិយមអស់ជាច្រើនឆ្នាំ។ ដោយច្បាប់នេះត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ។

សេចក្តីត្រូវការនៃច្បាប់ខាងលើត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ដើម្បីកំណត់ក្របខណ្ឌគតិយុត្តនៃនីតិវិធីចំណាយ និងចំណូលសាធារណៈ។ ដោយសារភារកិច្ចនេះមានសារៈសំខាន់ដែល ជាអាយុជីវិតជាតិទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តមុនច្បាប់ដ៏ទៃទៀត។ រហូតមកដល់ឆ្នាំ១៩៩៦ ដើម្បីអភិវឌ្ឍប្រទេសជាតិបានឆាប់រហ័ស រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្ត ប្រព័ន្ធវិមជ្ឈការ ដោយបានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ ខេត្ត ក្រុងព្រោះស្ថិតនៅជិត នឹងប្រជាពលរដ្ឋ ។ រាជរដ្ឋាភិបាលបានចេញជាអនុក្រឹត្យលេខ ០៧ អនក្របកចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៦ ស្តីពីចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង បន្ទាប់មក ក៏បានបង្កើតឲ្យទៅជាច្បាប់ពេញលេញ ដែលហៅថា **ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង** ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។ ចាប់ពីពេលនោះមកប្រព័ន្ធថវិការដ្ឋចាប់ផ្តើមមានពីរថ្នាក់គឺ ថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុង។ ក្រោយមកក៏មានការដាក់ឲ្យប្រើប្រាស់នូវ **ច្បាប់ស្តីពី ការគ្រប់គ្រងឃុំ សង្កាត់** នាឆ្នាំ២០០១ និង**ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤។

ជាបន្ថែមទៀតព្រះរាជាណាចក្រកម្ពុជាបានយល់ឃើញអំពី តម្លៃនៃទំនាក់ទំនងអន្តរជាតិក្នុងការជួយស្តារ និងកសាងប្រទេសជាតិ ហើយក៏បានធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលក្នុងតំបន់ អាស៊ាន និងពិភពលោក ។ គុណវិបត្តិនៃសមាហរណកម្មសេដ្ឋកិច្ចនេះ បានធ្វើឲ្យពន្ធគយថយចុះរហូតដល់សូន្យ ដែលធ្វើឲ្យប៉ះពាល់ដល់ចំណូលថវិការដ្ឋ។ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលប្រព័ន្ធថវិការដ្ឋដោយបង្កើនចំណូលផ្ទៃក្នុងដើម្បីទប់ទល់ចំណាយ តាមរយៈការអនុវត្តប្រព័ន្ធវិមជ្ឈការ និង ប្រព័ន្ធហិរញ្ញវត្ថុ ឲ្យទៅជាបីថ្នាក់គឺថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង សម្រួលច្បាប់ស្តីពី ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដើម្បីធានាបាននូវការអភិវឌ្ឍជនបទឲ្យបានខ្លាំងក្លា និងភាពជឿជាក់លើថវិការដ្ឋ សំដៅធានាបាននូវការប្រមូលធនធានហិរញ្ញវត្ថុឲ្យបានល្អប្រសើរ ។

២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទមួយនេះ គឺផ្តោតសំខាន់ទៅលើរបបហិរញ្ញវត្ថុដែលទាក់ទងទៅនឹង ការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យថវិកា ឃុំ សង្កាត់ នៅព្រះរាជាណាចក្រកម្ពុជា ពីព្រោះបច្ចុប្បន្ននេះឃើញថា

ការប្រើប្រាស់ហិរញ្ញវត្ថុរបស់រដ្ឋបាល ឃុំ សង្កាត់ មានការរីកចម្រើនគ្រប់ទិសទីនៃបណ្តា ឃុំ សង្កាត់ ពាសពេញផ្ទៃប្រទេស។ ទន្ទឹមនឹងនេះ ក៏ប្រទះឃើញមានបញ្ហាជាច្រើនបានកើតឡើង ដូចជាការប្រើប្រាស់ថវិកាក្នុងទម្រង់ពុករលួយពីសំណាក់មន្ត្រីរាជការមួយចំនួន ឆបោកដោយមិនបានបំពេញលក្ខខណ្ឌផ្លូវច្បាប់បានត្រឹមត្រូវជាដើម ។ ដូច្នេះជាចំណោទបញ្ហាដែលចោទសួរក្នុងប្រធានបទនេះមានដូចខាងក្រោម៖

- តើរដ្ឋបាល ឃុំ សង្កាត់ និង អនុវត្តថវិកាយ៉ាងដូចម្តេចខ្លះ?
- តើមន្ត្រីរដ្ឋបាល ឃុំ សង្កាត់ ធ្វើយ៉ាងណាទើបអាចប្រើប្រាស់ហិរញ្ញវត្ថុ មានលក្ខណៈត្រឹមត្រូវដោយគ្មានហានិភ័យ និងស្របច្បាប់នៅប្រទេសកម្ពុជា?
- តើដំណើរការនៃការត្រួតពិនិត្យថវិការបស់រដ្ឋបាល ឃុំ សង្កាត់ ប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើថវិកា ឃុំ សង្កាត់ មានប្រវត្តិយ៉ាងដូចម្តេច?
- ក្នុងករណីមានវិវាទកើតចេញពីការប្រើប្រាស់ថវិកាតើត្រូវដោះស្រាយដោយរបៀបណា?

៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងចូលរួមចំណែកពង្រឹងថវិកា ឃុំ សង្កាត់ឲ្យកាន់តែមានប្រសិទ្ធភាពនៅកម្ពុជា និងឱ្យមានការគោរពភាពត្រឹមត្រូវទៅតាមលក្ខណៈច្បាប់ និងស្តង់ដារនៃការអភិវឌ្ឍ ឃុំ សង្កាត់ ព្រមទាំងធានាប្រសិទ្ធភាព និង និរន្តរ៍ភាព។ ម្យ៉ាងទៀត ធានាឱ្យមានសន្តិសុខ សុវត្ថិភាព និង ការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ជាពិសេសចូលរួមលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម កិច្ចការពារបរិស្ថាន និងឱ្យមានការយល់ដឹងពីនីតិវិធីនៃការប្រើប្រាស់ថវិកា ឃុំ សង្កាត់ ប្រភពចំណូល ចំណាយផ្សេងៗនៅ ឃុំ សង្កាត់ក្នុងគោលដៅកាត់បន្ថយការយល់ច្រឡំ ឬ ការងឿងឆ្ងល់ពីសំណាក់ប្រជាពលរដ្ឋ និងជាចំណេះដឹងមួយដែលពលរដ្ឋគ្រប់រូបគួរតែស្វែងយល់ពីការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិកា ឃុំ សង្កាត់។

៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងក្នុងចំណោមចំណោទបញ្ហាខាងលើ សារណានេះត្រូវបានធ្វើការស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋាន គឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុងឆ្នាំ១៩៩៨ ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ច្បាប់ស្តីពី ការគ្រប់គ្រងឃុំ សង្កាត់ឆ្នាំ២០០១ អនុក្រឹត្យស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋបាលឃុំ សង្កាត់

សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានឆ្នាំ២០១៩ និងឯកសារមួយចំនួនដែល ជាប់ពាក់ព័ន្ធទាំងឡាយណាដូច បានលើកឡើងក្នុងឯកសារយោងដែលមានស្រាប់ដើម្បីសរសេរសារណានេះ។

គួរបញ្ជាក់ផងដែរថាសារណានេះ សិក្សាស៊ីជម្រៅតែលើលក្ខខណ្ឌផ្លូវច្បាប់ក្នុងការរៀបចំ ការអនុវត្ត និង ការត្រួតពិនិត្យថវិកាឃុំ សង្កាត់ យ៉ាងណាឲ្យមានភាពត្រឹមត្រូវតាមច្បាប់ និងការធ្វើបែបណាឲ្យមាន អានុភាពគតិយុត្ត ព្រមទាំងសិក្សាពីដំណើរការនៃសិទ្ធិ និងការអនុម័ត ការអនុវត្តថវិកា និងការត្រួតពិនិត្យ លើការអនុវត្តផងដែរ។

៥. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឲ្យសារណាបញ្ចប់ការសិក្សាមួយនេះ ទទួលបានជោគជ័យស្របតាមគោលការណ៍ដែលសាលា បាន កំណត់ ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវទៅលើឯកសារផ្លូវច្បាប់នានាជាច្រើនដែលមានប្រភពច្បាស់លាស់ និង ចូលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឯកសារដែលបានដកស្រង់ចេញពីសៀវភៅ និងគេហៈទំព័រ ផ្សេងៗទៀតដែលសុទ្ធតែជាឯកសារមានការទទួលស្គាល់ជាផ្លូវការ។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និង ដកស្រង់ចេញពីប្រភពល្អៗដូចជា ការបកស្រាយរបស់អ្នកមានបទពិសោធន៍លើវិស័យនេះផ្ទាល់ មតិយោបល់ របស់មន្ត្រីជំនាញផ្នែកនេះផ្ទាល់តែម្តង។

៦. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះមានសារៈសំខាន់ចំពោះបុគ្គលណា ដែលមានបំណងប្រឡងចូលក្របខណ្ឌរដ្ឋ ចូលបម្រើការងារជា មន្ត្រីរាជការ ពិសេសគឺ សិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅប្រទេសកម្ពុជាឱ្យបានយល់ ដឹងអំពីលក្ខខណ្ឌទទួលបានសិទ្ធិក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាឃុំ សង្កាត់ ក្នុងការអភិវឌ្ឍ និង ការរៀបចំផែនការអភិវឌ្ឍឱ្យស្របតាមលក្ខខណ្ឌគោលនយោបាយដែលរដ្ឋាភិបាលបានកំណត់។ លើស ពីនេះក៏ជាប្រយោជន៍សម្រាប់និស្សិតគ្រប់រូបបានសិក្សាស្វែងយល់ពីនីតិវិធីក្នុងការរៀបចំ ការអនុវត្ត និង ការ ត្រួតពិនិត្យថវិកាឃុំ សង្កាត់ ជាទុនសម្រាប់ប្រើប្រាស់ក្នុងការប្រឡងធ្វើជាមន្ត្រីរាជការ បម្រើពលរដ្ឋដោយមាន ប្រសិទ្ធភាព ប្រកបដោយ វិជ្ជាជីវៈទៅថ្ងៃអនាគត ប្រឹក្សាយោបល់ជូនពលរដ្ឋរបស់ខ្លួនដែលមកពឹងពាក់ឲ្យជួយ ផ្តល់យោបល់ ឬការពារក្តី រឿងវិវាទផ្សេងៗទាក់ទងនឹងហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ហេតុដូច្នេះដើម្បីធ្វើការបកស្រាយឆ្លើយតបនឹងចំណោទបញ្ហារបស់ប្រធានបទឲ្យបានក្បោះក្បាយ និង លម្អិត ជាងនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះចែកចេញជា ៣ជំពូកដូចខាងក្រោម៖

ជំពូកទី១ បកស្រាយអំពីការច្បាប់អំពីសញ្ញាណទូទៅនៃចំណាត់ថ្នាក់ថវិកា ដែលក្នុងនោះវែកញែកចំណាត់ថ្នាក់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(១.១) និងចំណាត់ថ្នាក់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(១.២)

រីឯជំពូកទី២ បកស្រាយអំពី ការរៀបចំ ការអនុម័ត និង ការអនុវត្តថវិការដ្ឋបាលឃុំ សង្កាត់ដោយបង្ហាញអំពីការរៀបចំ និងអនុម័តថវិការដ្ឋបាលឃុំ សង្កាត់(២.១) បន្ទុក និង ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់ (២.២) និង ការអនុវត្តថវិការដ្ឋបាលឃុំ សង្កាត់ (២.៣)

ចំណែកឯជំពូកចុងក្រោយគឺជំពូកទី៣ បង្ហាញពីការត្រួតពិនិត្យលើការអនុវត្តថវិកាឃុំ សង្កាត់លើកឡើងពីការត្រួតពិនិត្យលើអាណាប័កដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង (៣.១)ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុដោយសវនកម្មផ្ទៃក្នុង (៣.២)

ដើម្បីយល់ជ្រាបឱ្យបានកាន់តែច្បាស់សូមធ្វើការបកស្រាយដូចតទៅ៖

ជំពូកទី១

សញ្ញាណទូទៅនៃចំណាត់ថ្នាក់ថវិការដ្ឋ

ជំពូកទី១
សញ្ញាណទូទៅនៃចំណាត់ថ្នាក់ថវិការដ្ឋ

ថវិការដ្ឋត្រូវបានបែងចែកជា ចំណាត់ថ្នាក់ជាពីរថ្នាក់ គឺថវិកាថ្នាក់ជាតិ និង ថវិកាឃុំ សង្កាត់ នៅឆ្នាំ ២០០២ នៅពេលដែលប្រព័ន្ធគ្រប់គ្រងរដ្ឋនៅសម័យនោះចាប់ផ្តើមមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមមជ្ឈការ មកប្រព័ន្ធរដ្ឋបាលវិមជ្ឈការ និង វិសហមជ្ឈការ។ ការរៀបចំរដ្ឋបាលវិមជ្ឈការ និង វិសហមជ្ឈការក្នុងគោលបំណងបង្កើតសេវាសាធារណៈ ឲ្យនៅជិតប្រជាពលរដ្ឋ នឹងឆ្លើយតបសេវាសាធារណៈបានឆាប់រហ័សជូនប្រជាពលរដ្ឋស្របតាមទស្សនៈថ្មីនៃរដ្ឋបាលសាធារណៈ គឺរដ្ឋ ជាអ្នកបង្កើតសេវា ហើយរាស្ត្រជាអ្នកប្រើប្រាស់សេវាសាធារណៈ ដែលវាផ្ទុយពីមុនរដ្ឋបាលមានន័យថា រដ្ឋជា អ្នកគ្រប់គ្រង រីឯ រាស្ត្រជាអ្នកដែលត្រូវរដ្ឋគ្រប់គ្រង។

នៅឆ្នាំ២០១១ ប្រព័ន្ធវិមជ្ឈការមានការអនុវត្តកាន់តែប្រសើរនៅកម្ពុជា ហេតុនេះថវិកា ថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តនៅព្រះរាជាអាណាចក្រកម្ពុជា។ ចាប់ពីពេលនោះមកច្បាប់ ថវិកាថ្នាក់ក្រោម ជាតិ ដែលមានបីកម្រិតគឺ ថវិការាជធានី-ខេត្ត ថវិកា ស្រុក ក្រុង ខណ្ឌ និង ថវិកាឃុំ សង្កាត់។ ថវិកាទាំងបីនេះ ហៅថា ថវិកាថ្នាក់ក្រោមជាតិ ប៉ុន្តែរបបគតិយុត្តនៃថវិកាឃុំ សង្កាត់មិនស្ថិតនៅក្នុងរបបគតិយុត្តនៃច្បាប់នេះទេ គឺអនុលោមតាមច្បាប់ថវិកា និង ការគ្រប់គ្រងថវិកាឃុំ សង្កាត់។

១.១.ចំណាត់ថ្នាក់ថវិកាថ្នាក់ជាតិ

ចំណាត់ថ្នាក់នៃថវិកាជាតិ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់គម្រោង និងចំណាត់ថ្នាក់មូលនិធិ។ វិធានលម្អិត និងការអនុវត្តចំណាត់ថ្នាក់នៃមាតិកាថវិកាខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[1]

១.១.១.ថវិកាទូទៅ

ថវិកា សំដៅដល់ផែនការហិរញ្ញវត្ថុរបស់រដ្ឋ ដែលត្រូវបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ រួមមាន ការគ្រោងចំណូល និងចំណាយ ការខ្ចី និងការធ្វើហិរញ្ញប្បទានបំពេញតុល្យភាពថវិកា ដើម្បីសម្រេចសមិទ្ធកម្ម ដែលបានគ្រោងទុក។[2]

[1] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា ២២ ឆ្នាំ២០២៣

[2] អ៊ុំ សារឹទ្ធ និង ប៊ុនវុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ២៥

ថវិកា គឺជាគណនីមួយដែលប្រមូលផ្តុំចំណូល និង ចំណាយ ទាំងអស់ក្នុងមួយឆ្នាំហើយដែលសភាបានអនុម័តឲ្យអនុវត្ត។[3]

- ✓ ចំណូលទាំងអស់ ត្រូវរិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។
- ✓ ថវិកាដែលត្រូវបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមូលដ្ឋានក្នុងការបញ្ជាចំណាយ។
- ✓ ចំណូល និង ចំណាយទាំងអស់ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។

ថវិកាជាតិ ឬថវិការដ្ឋ រួមមាន ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ឬថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាឧបម្ភ័ន្ធ និងគណនីពិសេសរតនាគារ។

ក.ថវិកាថ្នាក់ជាតិ

ថវិកាថ្នាក់ជាតិ សំដៅដល់ថវិការបស់ក្រសួង ស្ថាប័ន ដែលរួមមាន ថវិការដ្ឋបាលកណ្តាល ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាមន្ទីរជំនាញក្រោមឱវាទ ព្រមទាំងថវិកាអង្គភាពសាធារណៈប្រហាក់ប្រហែល។[4]

ខ.ថវិកាថ្នាក់ក្រោមជាតិ

អាស្រ័យតាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថវិកាឆ្នាំ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជាបីកម្រិតគឺ រដ្ឋបាលរាជធានី/ខេត្ត២៥ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ២០៣ និង រដ្ឋបាលឃុំ/សង្កាត់ ១៦៤៦។ ក្រុមការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ចូលថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបី ដែលទទួលបានការបែងចែកថវិកាពី នាយកដ្ឋានហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅក្នុងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីលើនេះទៀត រតនាគារ រាជធានី/ខេត្ត នឹងបញ្ចូលថវិកា លំអិតសម្រាប់រដ្ឋបាលឃុំ/សង្កាត់ ទៅតាមគម្រោងថវិការបស់ខ្លួនដែលបានស្នើរឡើងជាបណ្តោះអាសន្ន ។[5]

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់ថវិការដ្ឋបាលរាជធានី ខេត្ត ថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាល ឃុំ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

[3] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២២ ទីកន្លែងបោះពុម្ព ភ្នំពេញ ទំព័រ៨

[4] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ២៦

[5] ព្រឹទ្ធសភា ទិដ្ឋភាពទូទៅលើការបែងចែក និងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន ឆ្នាំបោះពុម្ព២០១៩ ការិយាល័យរបស់វិទ្យាស្ថានសភាកម្ពុជា ទំព័រ ៤

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត តាមវិធាន និងនីតិវិធីដូចមានកំណត់ក្នុងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[6]

១.១.២.ថវិកាឧបសម្ព័ន្ធ

ថវិកាឧបសម្ព័ន្ធនៅថ្នាក់ជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្មជាចម្បង ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធត្រូវបង្កើតនឹងលុបដោយច្បាប់ហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរឥណទានថវិការវាងថវិកាឧបសម្ព័ន្ធ និងប្រភេទថវិកាដទៃទៀតមិនត្រូវអនុញ្ញាតឡើយ។ វិធាន និងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធត្រូវកំណត់ដោយអនុក្រឹត្យ។

ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការសេវាសាធារណៈ មានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម និងរដ្ឋបាល ដោយអនុញ្ញាតឱ្យមានចំណូល ដោយឡែកម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតនឹងលុបដោយប្រកាសរបស់មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោង អនុម័ត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។ ការបង្វែរឥណទានថវិកា រវាងថវិកាឧបសម្ព័ន្ធ និងប្រភេទនៃថវិកាដទៃទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវអនុញ្ញាតឡើយ។ វិធាន និងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ដោយអនុក្រឹត្យ។[7]

១.១.៣.ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល

គ្រឹះស្ថានសាធារណៈរដ្ឋបាល ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានថវិកាស្វយ័ត។ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមគោលបំណងគោលនយោបាយ និងកម្មវិធីដែលកំណត់ដោយក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ និង ត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវជាអាណាព្យាបាលបច្ចេកទេស។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន ចំណូលផ្គាល់ និងជាយថាហេតុមានការឧបត្ថម្ភតុល្យភាព ដោយថវិការដ្ឋ និង ចំណូលផ្សេងៗ ។

[6] អ៊ុំ សារឹទ្ធ និង ប៊ុន រ៉ុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ២៧

[7] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា ១៩ ឆ្នាំ២០២៣

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដែលជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាណាព្យាបាលហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។[8]

កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ជាតិត្រូវ គ្រោង អនុញ្ញាត និង អនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។ វិធាន និងនីតិវិធីនៃការគ្រោង តាងចំណូល ចំណាយ ការអនុញ្ញាត និងការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

១.១.៤.គណនីពិសេសរតនាគារ

គណនីពិសេសរតនាគារ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្តដែលធ្វើប្រតិបត្តិការមានលក្ខណៈរដ្ឋបាលជាចម្បង សម្រាប់បម្រើដល់ការអនុវត្តគោលនយោបាយ ឬការបំពេញបេសកកម្មជាក់លាក់ណាមួយរបស់រាជរដ្ឋាភិបាលដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ គណនីពិសេសរតនាគារត្រូវបង្កើត និងលុបដោយច្បាប់ហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃគណនីពិសេសរតនាគារ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរតណាទានថវិការវាងគណនីពិសេសរតនាគារ និងប្រភេទថវិកាដទៃទៀតមិនត្រូវអនុញ្ញាតឡើយ។ វិធាន និងនីតិវិធីនៃការគ្រប់គ្រងគណនីពិសេសរតនាគារត្រូវកំណត់ដោយអនុក្រឹត្យ។[9]

១.២.ចំណាត់ថ្នាក់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានប្រពន្ធ័ហិរញ្ញវត្ថុ និងថវិកាចំនួនបីថ្នាក់គឺ ៖[10]

១- ថ្នាក់ ខេត្ត ក្រុង

២- ថ្នាក់ ស្រុក ខណ្ឌ

៣-ថ្នាក់ឃុំ សង្កាត់ (អនុក្រឹត្យលេខ ២៦ អនក្រ.បកចុះ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២)

[8] ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា ២១ ឆ្នាំ២០២៣

[9] ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា ២០ ឆ្នាំ២០២៣

[10] ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រា ៥២ ឆ្នាំ ២០០៨

រដ្ឋបាលឃុំ សង្កាត់អាចប្រើច្បាប់ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ។ ក្រោយមក ចាប់ពីឆ្នាំ ២០១១ មក ក៏មានការបែងចែកថវិការដ្ឋបាលថ្នាក់ក្រោមជាតិជា បី គឺថវិការដ្ឋបាលរាជធានី ខេត្ត ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ និងថវិការដ្ឋបាល ឃុំ សង្កាត់។

១.២.១.ប្រវត្តិ និង ការវិវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេលជាង១០ឆ្នាំ (១៩៧៩-១៩៩១) ប្រទេសកម្ពុជាមានរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសមួយដែលឈរលើទ្រឹស្តីសង្គមនិយម និងដែលបានកំណត់នៅលក្ខណៈប្រមូលផ្តុំនិយម (Centralisation) ។ របបនេះបានចាប់កំណើតពីចុងអាវុធ ដោយបានផ្តួលរំលំរបបព្រៃផ្សៃអមនុស្សធម៌គឺ របបកម្ពុជាប្រជាធិបតេយ្យ។ ផ្តើមចេញពីការគ្រប់គ្រងបែបប្រមូលផ្តុំអំណាចនៅថ្នាក់មជ្ឈឹម ទើបរាជរដ្ឋាភិបាលអណត្តិទី២បានសំរេចគ្រប់គ្រងថ្នាក់ឃុំ សង្កាត់ តាមប្រព័ន្ធវិមជ្ឈការ ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៤៦ថ្មី ក៏បានចែងថា "ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់" ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។ ម៉្យាងទៀត លទ្ធិប្រជាធិបតេយ្យទាមទារឲ្យមាន តម្លាភាព និងបើកចំហរដោយអនុញ្ញាតឲ្យមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ជាពិសេសការរអនុញ្ញាតឲ្យប្រជាពលរដ្ឋជាអ្នកត្រួតពិនិត្យកិច្ចការរដ្ឋ ពិសេស ចំណូល ចំណាយថវិការដ្ឋ។ ការអនុវត្តបែបនេះរាជរដ្ឋាភិបាលយល់ថា "ដើម្បីងាយជំរុញកិច្ចអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ច និងសង្គមរបស់យើងដែលបានខ្ទេចខ្ទាំដោយសារសង្គ្រាម មួយវិញទៀត ឃុំ សង្កាត់ ក៏ជាអ្នកនៅជិតនឹងប្រជាពលរដ្ឋផងដែរ"។[11]

ក. ដំណាក់កាលនៃការចាប់ផ្តើមអនុវត្តថវិកាថ្នាក់ក្រោមជាតិ

មកដល់ឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តនូវប្រព័ន្ធវិមជ្ឈការ។ នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦ រាជរដ្ឋាភិបាល បានកំណត់ជាបណ្តោះអាសន្ននូវមាត្រា ១២ ដល់មាត្រា ១៨ ដោយតម្រូវឲ្យខេត្ត ក្រុង មានថវិកាដាច់ដោយឡែក។ ហើយរាជរដ្ឋាភិបាល បានចេញជាអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៦ ស្តីពី "ចំណាយជាគុណប្រយោជន៍ ខេត្ត ក្រុង" ដូចមានចែងក្នុងមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨។ តែដោយអនុក្រឹត្យលេខ០៧អនក្រ.បក នេះតាក់តែងពុំសូវបានល្អទើប រាជរដ្ឋាភិបាល ក៏បានកែប្រែអត្ថបទអនុក្រឹត្យនេះទៅជាច្បាប់តែម្តងដើម្បីឲ្យមានលក្ខណៈបច្ចេកទេសពេញលេញដែលហៅថាច្បាប់ស្តីពី របបហិរញ្ញវត្ថុ និង

[11] ព្រឹទ្ធសភា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទីកន្លែងបោះពុម្ព រាជធានីភ្នំពេញ ទំព័រ ៩

ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ។ ច្បាប់នេះ ត្រូវបានប្រកាសឲ្យប្រើនាថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨ តាមរយៈ ព្រះរាជក្រមលេខ ជស/រកម/០៣ ។

ចាប់ពីពេលនោះមក ប្រព័ន្ធថវិការដ្ឋចាប់ផ្តើមបែងចែកជាពីរថ្នាក់គឺ ថ្នាក់ជាតិ និង ថ្នាក់ខេត្ត ក្រុង។ ក្នុងច្បាប់នេះបានកំណត់ថា នៅក្នុងវិស័យហិរញ្ញវត្ថុ អភិបាលខេត្ត ក្រុង ជាអ្នកទទួលអនុវត្តបន្តនូវអំណាចរបស់រដ្ឋ និងស្ថិតនៅក្រោមរដ្ឋមន្ត្រីដែលជាសមត្ថកិច្ច ។ អភិបាលខេត្ត ក្រុងជាអ្នករៀបចំថវិការបស់ ខេត្ត ក្រុង។ របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខេត្ត ក្រុង ទទួលបន្ទុកគ្រប់គ្រងកិច្ចការក្នុងមណ្ឌលដែនដីរបស់ខ្លួនដើម្បីធានាឲ្យសេវាសាធារណៈ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋ ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្រុង របស់ខ្លួន។ ថវិកាខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមបទបញ្ញាត្តិទាំងឡាយនៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣។

១.២.២.ថវិការដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្ត ដែលទទួលបានមុខងារប្រតិភូកម្មពីក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណូលពីសេវាសាធារណៈទៅតាមប្រភេទសេវាសាធារណៈនីមួយៗដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន។ នៅក្នុងអំឡុងខែធ្នូ នៃឆ្នាំរៀបចំគម្រោងថវិកា រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវធ្វើគម្រោងចំណូលថវិកាប្រចាំឆ្នាំចំនួនមួយច្បាប់ លើប្រភេទសេវាសាធារណៈដែលទទួលបានមុខងារប្រតិភូកម្ម ទៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីបូកសរុបនឹងផ្ញើជូនក្រសួងពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងចំណូលថវិកាតាមវិស័យ។[12] នៅក្នុងឆ្នាំអនុវត្ត រដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលទទួលបានមុខងារប្រតិភូកម្ម ត្រូវប្រមូលចំណូលពី សេវាសាធារណៈ បង់ចំណូល និងកត់ត្រាជាចំណូលថវិការបស់ថ្នាក់រដ្ឋបាលសាមី។ ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដែលអនុវត្តដោយអង្គភាពរដ្ឋបាលកណ្តាល ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់សម្រាប់របាយការណ៍ប្រចាំខែ នឹងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់សម្រាប់របាយការណ៍ប្រចាំឆ្នាំ។[13]

រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំលើប្រភេទសេវាសាធារណៈដែលទទួលបានមុខងារប្រតិភូកម្ម បញ្ជូនទៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តដើម្បីបូកសរុប និងផ្ញើជូនក្រសួងពាណិជ្ជកម្ម ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា

[12] ព្រឹទ្ធសភា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ រាជធានីភ្នំពេញ ទំព័រ ១២

[13] ព្រឹទ្ធសភា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ រាជធានីភ្នំពេញ ទំព័រ ១២

នៃឆ្នាំបន្ទាប់សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ត្រូវបាននិរាករណ៍ប្រកាសរួម និងប្រកាសអន្តរក្រសួង ដូចខាងក្រោម៖[14]

១- ប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

២-ប្រកាសអន្តរក្រសួងលេខ៣៣៣ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលតម្លៃសេវា សាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

១.២.៣.ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ

ការបង្កើតឲ្យមានមូលនិធិក្រុង ស្រុក ដែលមានគណនីដោយឡែកនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិ ផ្ទេរគ្មានភ្ជាប់លក្ខណ្ឌពីថវិកាជាតិ និងទទួលធនធានពីប្រភពផ្សេងៗទៀត សម្រាប់ជាប្រយោជន៍ដល់ថវិការដ្ឋបាលក្រុង និង ស្រុក។ មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវផ្ទេរពីថ្នាក់ជាតិ ទៅមូលនិធិក្រុង ស្រុក ត្រូវធ្វើឡើងជាដំណាក់កាលៗក្នុងឆ្នាំនីមួយៗ តាមរូបមន្ត ឬ អត្រាជាក់លាក់ និងអាចប៉ាន់ប្រមាណបានសម្រាប់រយៈពេលមធ្យម។

ការវិភាជន៍ធនធានពីមូលនិធិក្រុង ស្រុកជូនទៅរដ្ឋបាលថ្នាក់ក្រុង ស្រុកនីមួយៗ ត្រូវធ្វើឡើងប្រចាំឆ្នាំដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងរូបមន្តប្រកបដោយតម្លាភាព។ ការបង្កើត និងវិធានអនុវត្តរបស់មូលនិធិក្រុង ស្រុក ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីមន្ត្រីក្រសួងមហាផ្ទៃ។[15]

ក. ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុកត្រូវកំណត់សម្រាប់ថេរវេលាចំនួនប្រាំឆ្នាំ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដោយគិតជាសមាមាត្រលើចំណូលចរន្តថវិកាជាតិមានដូចខាងក្រោម ៖[16]

- ឆ្នាំថវិកា២០១៩ មានចំនួន ១,១ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៨
- ឆ្នាំថវិកា២០២០ មានចំនួន ១,២ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៩
- ឆ្នាំថវិកា២០២១ មានចំនួន ១,៣ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២០

[14] ព្រឹទ្ធសភា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ រាជធានីភ្នំពេញ ទំព័រ ១៣

[15] ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មាត្រា៣១ ឆ្នាំ ២០១១

[16] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា៤

- ឆ្នាំថវិកា២០២២ មានចំនួន ១,៤ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២១
- ឆ្នាំថវិកា២០២៣ មានចំនួន ១,៥ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២២។

ខ.ការវិភាជ ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

ធនធានមូលនិធិក្រុង ស្រុកត្រូវចែកចេញជាពីរសមាសភាគដូចខាងក្រោម៖[17]

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម៖

(ក) ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានកំណត់ដោយផ្អែកលើឯកតាវង្វាស់និងនិយាមដូចខាងក្រោម៖[18]

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុកនិងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្សសម្រាប់ប្រភេទនីមួយៗ
- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀតមិនឲ្យលើសពី ២៥ ភាគរយនៃធនធានមូលនិធិសរុប ដក ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

(ខ). ទំហំធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹង ធនធានវិភាជន៍សរុប ដក ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ។

ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុកត្រូវបានបែងចែកទៅឲ្យរដ្ឋបាលក្រុង ស្រុកនីមួយៗស្របតាមវិធានដូចខាងក្រោម៖[19]

(១).ធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានវិភាជន៍ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗដោយអនុលោមតាមនិយាមដូចខាងក្រោម ៖

ក. ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ. ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណអភិបាលក្រុង ស្រុក

[17] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា ៥

[18] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា៥

[19] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា ៥

គ. ចំណាយប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុកផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ

ឃ. ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅឲ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖[20]

- ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សា និងចំនួន សមាជិកគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រានៃចំនួនមន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ

(២).ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបានវិភាជទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖[21]

ក.ចំនួន ៤០ ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាល ក្រុង ស្រុកនីមួយៗ

ខ.ចំនួន ២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជននៃរដ្ឋបាលក្រុង ស្រុក នីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ.ចំនួន ៤០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាម ទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។ លក្ខណៈវិនិច្ឆ័យ និងចំនួនភាគរយនៃសន្ទស្សន៍នីមួយៗសម្រាប់ធ្វើការបែងចែកធនធានសមាសភាគ អភិវឌ្ឍន៍មូលដ្ឋានអាចត្រូវបានពិនិត្យ និងកែលម្អឡើងវិញនាពេលមួយសមស្របក្រោមហេតុផលនៃយុត្តិកម្ម គោលនយោបាយដើម្បីធានាបាននូវសមធម៌នៃការវិភាជធនធានដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុកដើម្បីផ្តល់ហិរញ្ញប្បទាន ដល់ចំណាយចំណែកណាមួយបានលុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាក្រុង ស្រុកដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល

[20] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា៥

[21] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា ៥

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋាននានាដទៃទៀតដែលមានជាធរមាន។

១. ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគរដ្ឋបាលទូទៅ៖

(ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក

(ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យគ្រឿងសង្ហារឹមមធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

២. ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ៖

(ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ។

(ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។ ការប្រើប្រាស់ ធនធាននៃមូលនិធិសមាសភាគក្នុងចំណុចទី១ និងចំណុចទី២ ខាងលើនេះ គឺជាឆន្ទានុសិទ្ធិ របស់រដ្ឋបាលក្រុង ស្រុក នីមួយៗ ដែលត្រូវបានរៀបចំតាមចំណាត់ថ្នាក់នៃមាតិកាថវិកាដែលកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបោះពុម្ពផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិក្រុង ស្រុក ជា០៤(បួន) លើក សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម ៖[22]

- លើកទី១ + ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី១
- លើកទី២ ៖ ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី២
- លើកទី៣ + ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី៣
- លើកទី៤ - ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី៤។

គ.ចំណាយរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ

ចំណាយថវិកា របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានដូចជា៖ [23]

១- ជួសជុលថែទាំទីស្នាក់ការក្រុង ស្រុក ខណ្ឌ ឬការជួសជុលផ្ទះ ឬបន្ទប់ប្រសិនបើមាន។

២- សោហ៊ុយចំណាយថែរក្សាលិខិត និងឯកសារទាំងឡាយដែលជាបន្ទុករបស់ ក្រុង ស្រុក ខណ្ឌ ។

៣- ចំណាយបៀវត្ស និងប្រាក់បំណាច់របស់បុគ្គលិក

[22] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៤ មាត្រា ៦

[23] សៀវភៅថវិកាក្រុង ស្រុក ឆ្នាំ២០១៩ ទំព័រ ៤

៤- សោហ៊ុយចំណាយដំណើរការរបស់សេវារដ្ឋបាលដែលស្ថិតនៅក្រោមសមត្ថកិច្ចក្រុង ស្រុក ខណ្ឌ ព្រមទាំងសេវាសាធារណៈមានជាអាទិ៍ ដូចជា ការបំភ្លឺសាធារណៈ ការប្រឆាំងនឹងអគ្គីភ័យ ការប្រមូលសំរាម និងអន្តរាគមន៍ក្នុងវិស័យជំនួយសង្គមកិច្ច អនាម័យ សុខាភិបាល ។

៥- ចំណាយសំរាប់ការរៀបចំ ការថែទាំ និងការជួសជុលធំ នូវសំណង់អគារសាធារណៈ បរិក្ខាសមូហភាព គ្រប់ប្រភេទដែលរដ្ឋប្រគល់ឲ្យក្រុង ស្រុក ខណ្ឌ កាន់កាប់មានជាអាទិ៍ដូចជា អគាររដ្ឋបាល អគារសិក្សា មន្ទីរពេទ្យ ទីផ្សារសាធារណៈ បរិក្ខាកីឡា និងវប្បធម៌។

៦-សោហ៊ុយចំណាយថែទាំផ្លូវថ្នល់ និងសួនច្បារសាធារណៈ។

៧-សោហ៊ុយចំណាយសំរាប់ថែទាំប្រឡាយលូ អណ្តូងទឹក ក្បាលម៉ាស៊ីនទឹក ប្រឡាយបង្ហូរទឹកមិនស្អាត។

៨-ចំណាយទាំងឡាយណាដែលស្ថិតក្នុងបន្ទុករបស់ក្រុង ស្រុក ខណ្ឌ ដែលច្បាប់ឬបទបញ្ញត្តិដែលបានកំណត់៖ ចំណាយបន្ទាប់បន្សំ សោហ៊ុយទទួលភ្ញៀវ ការប្រជុំ និងសំរាប់ដំណើរទស្សនកិច្ចផ្សេងៗ។ ខ្លះចំណាយទាំងនោះអាចគ្រោងបានតែនៅក្នុងករណី ដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់ និងមិនធ្វើឲ្យបាត់តុល្យភាពថវិកា ។

១.២.៤.ថវិការដ្ឋបាល ឃុំ សង្កាត់

ក. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ត្រូវបានបង្កើតឡើងនៅសម័យអាណានិគមបារាំងក្នុងឆ្នាំ១៩០៨ តែមិនបានអនុវត្តទេ។ ការអនុវត្តពិតប្រាកដធ្វើឡើងតាមព្រះរាជប្រកាស ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ និងត្រូវបានកែប្រែ។ ក្រោយមកក៏មានការធ្វើវិសោធនកម្មក្នុងឆ្នាំ១៩២៤ ដោយអនុញ្ញាតឱ្យឃុំ សង្កាត់មានថវិកា។ រដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតឱ្យមានឡើងវិញនៅ ថវិការដ្ឋបាលឃុំ សង្កាត់ តាមសេចក្តីសម្រេចលេខ១០០ សសរ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៨៧ ស្តីពីការបង្កើតថវិកាឃុំ សង្កាត់។ ព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។[24]

តើថវិការដ្ឋបាលឃុំ សង្កាត់ ទទួលបានពីប្រភពណា?

ថវិការដ្ឋបាលឃុំ សង្កាត់ ទទួលបានពីប្រភពដូចខាងក្រោម៖[25]

(១) បានមកពីថ្នាក់ជាតិ៖ គឺជារៀងរាល់ឆ្នាំ ឬ៣ឆ្នាំ ឬក៏៥ឆ្នាំ នឹងមានការទម្លាក់ទៅតាមផែនការដែលស្នើរពីថ្នាក់ក្រោមជាតិទៅ ហើយថ្នាក់ជាតិធ្វើការសម្រេចដើម្បីផ្តល់ថវិកានេះជូនថ្នាក់ក្រោមជាតិ។

[24] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤១

[25] youtube: https://youtu.be/Q1MFUrBQ8Mc?si=JHYXnnpsBVb0cXaM ចូលមើលថ្ងៃទី៦ឧសភា២០២៤

(២) បានមកពីចំណូលផ្ទាល់៖ បានមកពីសេវាផ្សេងទៀតដែលមាននៅក្នុងស្តង់ដារ (ការចុះបញ្ជីដីធ្លី ការស្នើរសុំធ្វើលិខិតស្នាមផ្សេងៗ) ដែលជាចំណូលហិរញ្ញវត្ថុក្នុងឃុំទទួលបាន។

(៣) បានមកពីមូនិធិឃុំ សង្កាត់៖ ជាទូទៅឃុំ សង្កាត់ទទួលបានកញ្ចប់ថវិកាប្រចាំឆ្នាំជាចំណូលមួយដែលផ្ទេរពីថវិការបស់រដ្ឋាភិបាល។

(៤) បានមកពីការអនុវត្តមុខងាររបស់គាត់៖មានន័យថាគាត់បានទទួលភារៈកិច្ចបំពេញមុខងារភ្នាក់ងារនៅឃុំ ជំនួសឲ្យមុខងាររដ្ឋ ក៏ដូចជាមុខងារក្រសួងស្ថាប័នផ្សេងៗដែលផ្ទេរមុខងារទៅឲ្យគាត់អនុវត្ត ដើម្បីទទួលបានសិទ្ធិបានទទួលនៅចំណូលបន្ថែមទៀតដែរ ហើយអ្វីដែលឃុំ សង្កាត់ទទួលបានចំណូលខ្ពស់ជាងគេនោះ រដ្ឋបាល ឃុំគឺ ការវិភាជន៍ពីថ្នាក់ជាតិទៅ។

ខ.ថវិការដ្ឋបាល ឃុំ សង្កាត់

ស្វ័យភាពថវិការដ្ឋបាលឃុំ សង្កាត់ ត្រូវបានទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ ដោយចាប់ផ្តើមពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាលើកដំបូងនៅឆ្នាំ២០០២ ក៏ដូចជាការអនុវត្តថវិកា ឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការអំណាចនៅថ្នាក់មូលដ្ឋាន ដោយអនុញ្ញាតឱ្យរដ្ឋបាលឃុំ សង្កាត់ ទទួលបានធនធាន ហិរញ្ញវត្ថុ ថវិកា និង ទ្រព្យសម្បត្តិផ្ទាល់ សម្រាប់ដំណើរការការងារនៅមូលដ្ឋានខ្លួន។ រដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូល មិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។ ពន្ធខាងលើនេះរាប់បញ្ចូលពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធពីការជួល។

ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលឃុំ សង្កាត់ ការប្រមូលនេះត្រូវធ្វើក្នុងនាមរដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់ ទទួលបានធនធានវិភាជន៍ពីចំណូលរដ្ឋសម្រាប់ថវិការបស់ខ្លួន។

គ.ធនធានវិភាជន៍នៃថវិកាឃុំ សង្កាត់

ធនធានវិភាន៍នៃថវិកាឃុំ សង្កាត់ រួមមាន៖[26]

- ការផ្ទេរទាំងមូល ឬមួយផ្នែកនូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាន និងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទាន ដែលបានមកពីប្រាក់ចំណូលរដ្ឋ
- ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅរដ្ឋបាលឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង។

[26] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ មាត្រា៧៣-៧៤

លើសពីនេះរដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិ៖

- ទទួលបាននូវប្រាក់កម្រៃ ចំពោះការអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ដែលរដ្ឋាភិបាល ក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត
- ប្រាក់កម្រៃខាងលើនេះ គឺជាប្រាក់បន្ថែមពីលើចំណូលរបស់រដ្ឋបាលឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗ ដែលរដ្ឋបាលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ។

ក្នុងករណី ការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យរដ្ឋបាល ឃុំ សង្កាត់ រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសម្រាប់ផ្តល់ឲ្យរដ្ឋបាល ឃុំ សង្កាត់។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាល ឃុំ សង្កាត់ និងនីតិវិធីដែលទាក់ទងនឹងការងារដូចខាងក្រោម៖[27]

- ថវិការដ្ឋបាល ឃុំ សង្កាត់
- ប្រព័ន្ធគណនេយ្យ និង ប្រព័ន្ធទូទាត់ សម្រាប់រដ្ឋបាល ឃុំ សង្កាត់
- ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់
- ទ្រព្យសម្បត្តិរដ្ឋបាលឃុំ សង្កាត់
- សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។[28]

ឃ. ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់រួមមានបីប្រភេទ ៖[29]

១-ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិអោយកាន់កាប់

២-ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯង

៣-ទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។

ចាប់ពីជំពូកទី២ ទៅនឹងសង្កត់ធ្ងន់លើការអនុវត្ត ថវិកា ឃុំ សង្កាត់ ដែលមានចែងក្នុងច្បាប់ថ្មីៗ។

[27] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ មាត្រា៧៣-៧៤

[28] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ មាត្រា៧៦

[29] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ មាត្រា៤៩

ជំពូកទី២

ការរៀបចំ ការអនុម័ត និង ការអនុវត្ត ថវិការដ្ឋបាលឃុំ សង្កាត់

ជំពូកទី២

ការរៀបចំ ការអនុម័ត និង ការអនុវត្តថវិការដ្ឋបាលឃុំ សង្កាត់

២.១ ការរៀបចំ និងអនុម័តថវិការឃុំ សង្កាត់

គម្រោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យនិងអនុម័ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី ៣១ ខែ តុលា។ ហើយការអនុម័តនោះត្រូវធ្វើឡើងតាមផ្នែក និងប្រភេទនីមួយៗនៃគម្រោងថវិកា។ មេឃុំ ចៅសង្កាត់ត្រូវធានាឲ្យមានការចូលរួមពីសាធារណៈជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោមនេះ៖[30]

- គម្រោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈយ៉ាងតិច ២សប្តាហ៍មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវបើកចំហដល់សាធារណៈជនដែលចាប់អារម្មណ៍លើការពិនិត្យគម្រោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាព ក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលសម្រេចលើគម្រោងថវិកា
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗ ដើម្បីជម្រុញឲ្យមានការចូលរួមពីសាធារណជនលើកិច្ចការមូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្តថ្ងៃទី ៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់។ គម្រោងថវិកានោះត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោមនេះ៖[31]

- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយ ព្រមទាំងកម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិការនៃឆ្នាំដំណើរការ
- តារាងសង្ខេបនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ចាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រសិនបើមាន
- កំណត់ហេតុស្តីពីកិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

[30] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ លេខ១៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ មាត្រា១១-១២

[31] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ លេខ១៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ មាត្រា១៣

អភិបាលខេត្ត ក្រុង ត្រូវពិនិត្យអនុលោមភាព (compliance controls) និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី ៣០ ខែ វិច្ឆិកា។ ហើយការត្រួតពិនិត្យអនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោមនេះ៖[32]

(១) ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំថវិកា

(២) តុល្យភាពថវិកា និង ការប្រើប្រាស់ចំណូលមូលធន

(៣) លំក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលទទួលបាន

(៤) ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

(៥) តម្រូវការថវិកាវិនិយោគ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការរបស់ឃុំ សង្កាត់។

អភិបាលខេត្ត ក្រុង មិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រៅពីពិនិត្យលើលំក្ខខ័ណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព។ ប្រសិនបើគម្រោងថវិកាត្រូវបានបំពេញតាមលំក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាព អភិបាលខេត្តក្រុងត្រូវបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយលក្ខអក្សរជូនប្រធានក្រុម ប្រឹក្សាឃុំ សង្កាត់។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកាដែលមាន ហត្ថលេខាសង្ខេបរបស់អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ។ ទន្ទឹមគ្នានេះ អភិបាលខេត្ត ក្រុងត្រូវចម្លងជូនសេចក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង ។

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងជាបន្ទាន់ជាលាយលក្ខអក្សរដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដោយបញ្ជាក់ពីមូលហេតុ ហើយណែនាំដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យអនុវត្តវិធានការកែតម្រូវ។ មេឃុំ ចៅសង្កាត់ត្រូវពិនិត្យកែសម្រួលគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់ ១៥ ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាលខេត្ត ក្រុង។ បន្ទាប់ពីការពិភាក្សាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ផ្ញើគម្រោងថវិកាតម្រូវជូនអភិបាលខេត្ត ក្នុងការបញ្ជាក់ទទួលស្គាល់។ បើសិន ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ខកខានមិនបានបញ្ជូនគេម្រោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាលខេត្ត ក្រុង ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬ គម្រោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះអភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសម្រួល

[32] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ លេខ១៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ មាត្រា១៤

ចាំបាច់មុនពេលបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា។ អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង។

ក្នុងករណីមានការមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយអភិបាលខេត្ត ក្រុង ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបញ្ជូនករណីនេះទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសម្រេច។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃចាត់ទុកជាការសម្រេចចុងក្រោយ។ ក្នុងករណី អភិបាលខេត្ត ក្រុង មិនបានបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាតឲ្យអនុវត្តជាបណ្តោះអាសន្នលើចំណាយប្រចាំខែក្នុងកម្រិត ១/១២ នៃថវិកាដែលបានអនុម័តឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាមលិក្ខខ័ណ្ឌដែលបានអនុម័តដូចឆ្នាំមុនដែរ។[33]

២.១.១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

រដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពី ការផ្ទេរធនធានថវិការដ្ឋដល់ ឃុំ សង្កាត់ បន្ថែមដើម្បីដល់ការអភិវឌ្ឍមូលដ្ឋានរយៈពេល ៥ ឆ្នាំ ពី ២០២៤ ដល់ឆ្នាំ ២០២៨ ក្នុងគោលដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន ដែលរដ្ឋគ្រោងចំណាយ ១ឆ្នាំ ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ។[34] អនុក្រឹត្យនេះបានសង្គមស៊ីវិលសាទរចំពោះការផ្តល់ថវិការសម្រាប់ចំណាយដល់មូលដ្ឋានសម្រាប់ការអភិវឌ្ឍឃុំ សង្កាត់ ហើយអាចបង្កលទ្ធភាពដល់តម្រូវការមូលដ្ឋានមួយចំនួន។ យោងតាមអនុក្រឹត្យចុះថ្ងៃទី១០ ខែកក្កដា កន្លងទៅដែលចុះហត្ថលេខាដោយ សម្តេចតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋដល់រដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍនៅមូលដ្ឋានបានលើកឡើងថា អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរដ្ឋបាលឃុំ សង្កាត់ទាំងអស់លើកលែងភូមិសាស្ត្ររដ្ឋបាលចំណុះរាជធានីភ្នំពេញ។ អនុក្រឹត្យនេះបន្តថា រដ្ឋគ្រោងចំណាយក្នុងមួយឆ្នាំចំនួន ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលអនុម័តទុកមុន ១ឆ្នាំតួយ៉ាងថវិកាដែលត្រូវចំណាយលើរដ្ឋបាលឃុំ សង្កាត់នៅឆ្នាំ២០២៤ ត្រូវយក ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលអនុម័តនៅឆ្នាំ ២០២៣ ដែលជាភារកិច្ចគ្រប់គ្រងដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រភពដដែលបានបន្តទៀតថា រូបមន្ត និងសន្ទស្សន៍ដែលត្រូវចំណាយនៅរដ្ឋបាលមូលដ្ឋានមានដូចជា ៣០% ជាចំណែកស្មើៗគ្នា ដែលបែកចែកសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។ ៣០% ត្រូវបានបែងចែកតាមសមាមាត្រនៃចំនួនប្រជាជនរបស់ ឃុំ សង្កាត់នីមួយៗផ្អែកតាមទិន្នន័យក្រសួងផែនការ។ ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិការបស់រដ្ឋបាល និងឃុំ សង្កាត់ ត្រូវ

[33] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ លេខ១៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ មាត្រា១៤ -១៧

[34] អនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋដល់ឃុំ-សង្កាត់បន្ថែមដើម្បីចំណាយលើការអភិវឌ្ឍមូលដ្ឋានរយៈពេល ៥ឆ្នាំ ២០២៤-២០២៨

រៀបចំដោយអភិបាលនៃគណៈអភិបាល និងអនុម័តដោយក្រុមប្រឹក្សាទៅតាមនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម៖[35]

ដំណាក់កាលទី១: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនា ដល់ខែឧសភា)

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំពីការរៀបចំយុទ្ធសាស្ត្រថវិកាដល់គ្រប់ក្រសួងស្ថាប័ន អង្គភាព ទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និងគម្រោងថវិកាក្នុងវិស័យរបស់ខ្លួនដែលត្រូវអនុវត្តនៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ ផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនដោយ ឈរលើមូលដ្ឋានផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយដាក់បញ្ជូនក្រុមរបស់ខ្លួនដើម្បីពិនិត្យពិភាក្សា និងអនុម័តហើយត្រូវផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែឧសភា។

២.១.២ ការរៀបចំកញ្ចប់ថវិកា

ដំណាក់កាលទី២: ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)

នៅសប្តាហ៍ទី១នៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំសារាចរណែនាំ ស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងថវិកា និងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ហើយផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូលចំណាយថវិកាលំអិតរបស់ខ្លួន ។ អភិបាលនៃគណៈអភិបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានសារាចរណែនាំ ស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកា និងអាទិភាពគោលនយោបាយនៃរដ្ឋបាលរបស់ខ្លួន ដោយដាក់បញ្ចូលនូវរាល់ប្រភពថវិកាទាំងអស់ដែលត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឡើងដោយអភិបាល នៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនូវគម្រោងជាតិនីមួយៗ។ ដោយមានជំនួយពីប្រធានហិរញ្ញវត្ថុនៃក្រុមប្រឹក្សា និងមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ថវិកានេះដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ច

[35] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤៤

របស់ខ្លួនរួចហើយត្រូវពិនិត្យ និងរៀបចំឡើងវិញនូវគម្រោងថវិកានេះដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា។

ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្ម ឲ្យអភិបាលនៃគណៈអភិបាលខេត្តទទួលខុសត្រូវ ក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ព្រមទាំងបទបញ្ជា បែបបទ និងនីតិវិធីនានាដែលកំណត់ដោយថ្នាក់ជាតិ។ អភិបាលនៃគណៈអភិបាល ខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ ។ អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថាមន្ត្រី នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុបគម្រោងថវិការបស់ខេត្តគម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយភ្ជាប់មកជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយ ពន្យល់របស់ ខេត្ត ក្រុង ស្រុក ហើយត្រូវធ្វើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ។ ក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពលើថវិការបស់រាជធានី ថវិការបស់ខេត្ត ថវិការបស់ក្រុង និងថវិការបស់ស្រុក។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួន ឬអាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់។ ដំណើរការពិនិត្យនីត្យានុកូលភាពត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង និងស្រុក ដែលតំណាងឲ្យក្រុមប្រឹក្សាជាម្ចាស់ថវិកាតំណាងក្រសួងមហាផ្ទៃសមាសភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងដំណើរការពិនិត្យនីត្យានុកូលភាពនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ ទៅលើគោលការណ៍ នៃការពិនិត្យនីត្យានុកូលភាពដូចខាងក្រោម៖[36]

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ ចំណាត់ថ្នាក់ថវិកា បែបបទ និងនីតិវិធី ដែលបាន កំណត់។
- មានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា។
- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់ ។

[36] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤៥

- គម្រោងថវិកា ត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់ ដែលបានកំណត់ទុកជាមុន ។
- ធានាឲ្យមានតុល្យភាពពិតប្រាកដ រវាងចំណូល និងចំណាយថវិកា ។
- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ។

ក្នុងករណីដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យឃើញថាគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យនីត្យានុកូលភាពដូចបានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្រេចកែសម្រួល និងជូនដំណឹងជាលាយលក្ខអក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន ។

២.១.៣ ការអនុម័តថវិកា

ដំណាក់កាលទី៣ : ការអនុម័តថវិកា (ពីខែតុលា ដល់ធ្នូ)

នៅសប្តាហ៍ទី១ នៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី១ ខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី១ នៃខែធ្នូ ដើម្បីសម្រេចសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី២៥ ខែធ្នូ ។[37]

២.២ បន្ទុក និងធនធាន ហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់

បន្ទុក និង ធនធានហិរញ្ញវត្ថុ របស់រដ្ឋបាលឃុំ សង្កាត់ មានដូចជា ៖[38]

- ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
  - ចំណាយប្រតិបត្តិការរដ្ឋបាល
  - ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច
  - ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស
  - ចំណាយក្នុងការអនុវត្តតួនាទីភារកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត ។
- ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

[37] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤៧

[38] អ៊ុំ សារឹទ្ធ និង ប៊ុន វុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤៩

- ចំណូលពីប្រភពនៅមូលដ្ឋាន
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។[39]

២.២.១ បន្ទុក និងឆន្ទានហិរញ្ញវត្ថុរដ្ឋបាល ឃុំ

កថាខណ្ឌទី១ ៖ ការចំណាយថវិការបស់អង្គភាពថវិកាជាអាណាប័កផ្នែរសិទ្ធិ៖[40]

ក. សិទ្ធិអំណាច និង ការទទួលខុសត្រូវ

អង្គភាពថវិកា ដែលជាអាណាប័កផ្នែរសិទ្ធិ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

ក.១.ការរៀបចំថវិកា

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័នសាមី។
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាព ដែលស្ថិតក្រោមឱវាទទៅតាម ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗ ទៀតនៃមាតិកាថវិកា។
- ចូលរួមចរចារថវិកាកម្រិតជំនាញ និងកម្រិតថ្នាក់ដឹកនាំតាមការអញ្ជើញរបស់អាណាប័កដើមខ្សែ ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីចាំបាច់។

ក.២.ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួន ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំ ដែលវិភាជន៍ជូនដោយអាណាប័កដើមខ្សែ។
- រៀបចំគម្រោងកម្មវិធីចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសរួចបញ្ជូនមកអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នឲ្យបានទាន់ពេលវេលាកំណត់។
- អនុវត្តតាមកម្មវិធីចំណូល ចំណាយដែលក្រសួង ស្ថាប័នអាណាព្យាបាលកំណត់ឲ្យអនុវត្តតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។
- មានសិទ្ធិពេញលេញក្នុងកិច្ចប្រតិបត្តិការចំណូលរបស់ខ្លួន។
- មានសិទ្ធិពេញលេញក្នុងការរៀបចំ និងអនុវត្តកញ្ចប់រដ្ឋទេយ្យបុរេប្រទាន ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរដ្ឋបុរេប្រទានជាធរមាន។

[39] អ៊ុំ សារឹទ្ធ ឯកឧត្តម ប៊ុន រ៉ុទ្ធា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំបោះពុម្ព ២០១១ ទំព័រ ៤៩

[40] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ៥៧

- មានសិទ្ធិពេញលេញ ក្នុងការស្នើសុំគោលការណ៍ធានាចំណាយ និងស្នើសុំការទូទាត់ ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ថ្នាក់កណ្តាល និងទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ថ្នាក់រាជធានីខេត្ត ដើម្បីទទួលការទូទាត់ដោយផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារថ្នាក់រាជធានី ខេត្ត ដោយត្រូវគោរពទៅតាមក្របខណ្ឌនៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន និងស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ដែលមានចែងក្នុងគោលការណ៍ណែនាំ ស្តីពីនិតិវិធីអនុវត្តថវិកាកម្មវិធី។ អង្គភាពថវិកាអាចស្នើសុំការគាំទ្រ និងការសម្របសម្រួលពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ក្នុងករណីចាំបាច់ ប៉ុន្តែរាល់សំណើរសុំធានាចំណាយ និងទូទាត់ត្រូវចម្លងជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីតាមដានការអនុវត្តថវិកា និង បូកសរុបរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- អាចស្នើសុំធ្វើចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកា ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ដែលមានចែងក្នុងគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។
- អាណត្តិបើកប្រាក់ និងអាណត្តិនិយ័តកម្ម ត្រូវចុះលេខនៅអង្គភាពហិរញ្ញវត្ថុ។ ឯកសារពាក់ព័ន្ធរួមមានអាណត្តិបើកប្រាក់ លិខិតស្នើសុំធានាចំណាយ សាលាកបត្រកត់ត្រាចំណាយ ថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុអមដោយដីកាបញ្ចេញអាណត្តិបើកប្រាក់ និងដីកាអមលិខិតយុត្តិការ ត្រូវចតចម្លងជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់ជាកម្មវត្ថុកត់ត្រា បូកសរុប និងតាមដានត្រួតពិនិត្យវាយតម្លៃ។[41]

ក.៣.ការត្រួតពិនិត្យ និង តាមដានការអនុវត្តថវិកា

- ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មស្របតាមការណែនាំ របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬក្រុមការងារថវិកា ក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និង ផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទ ដែលបានកំណត់។
- ការអនុវត្តរបស់អង្គភាព ដែលជាអាណាប័កផ្ទេរសិទ្ធិត្រូវបង្កើតនិងស្នើសុំតែងតាំងដូចខាងក្រោម៖[42]

  ១. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

  ២. រដ្ឋទេយ្យការបុរេប្រទាន និងរដ្ឋទេយ្យការបុរេប្រទានរង

  ៣. រដ្ឋទេយ្យការចំណូល និងរដ្ឋទេយ្យការចំណូលរង

  ៤. ក្រុមលទ្ធកម្ម

[41] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ៥៧-៥៨

[42] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ៥៨

៥. ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកជំនួស។

ខ.នីតិវិធីចំណាយថវិកា

ការស្នើសុំគោលការណ៍ធានាចំណាយថវិកា និងការទូទាត់ ត្រូវដាក់ត្រង់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្នាល់ សម្រាប់រដ្ឋបាលថ្នាក់កណ្តាល និងទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការចំណាយ។ អភិបាលហិរញ្ញវត្ថុពិនិត្យ និង សម្រេច រួចបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ថ្នាក់កណ្តាល និងទៅរតនាគាររាជធានី ខេត្ត សម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ក្នុងនាមគណនេយ្យករសាធារណៈដើម្បីពិនិត្យ សម្រេច និងបើកផ្តល់សាច់ប្រាក់។ រាល់កិច្ចប្រតិបត្តិការគ្រប់គ្រងចំណាយថវិកា ត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ក្នុងនោះមានជាអាទិ៍៖[43]

- ត្រូវគោរពតាមឥណទានថវិកា ដែលបានវិភាជន៍ជូនពីដើមឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី។
- ត្រូវអនុវត្តចំណាយតាមកម្មវិធីចំណូល ចំណាយ ប្រចាំត្រីមាស ដែលក្នុងនោះបានចែកឥណទានថវិកាទៅតាមខែនីមួយៗ នៃឆ្នាំសារពើពន្ធ។ អង្គភាពថវិកាអាចបោះផ្សាយអាណត្តិបើកប្រាក់ក្នុងរង្វង់ នៃកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសរបស់ខ្លួន។
- កិច្ចប្រតិបត្តិការចំណាយថវិកាចរន្តត្រូវអនុវត្តតាមប្រភេទចំណាយ និងនីតិវិធីចំណាយដែលរួមមាន៖[44]

– ចំណាយមិនតម្រូវឲ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ជាប្រភេទចំណាយ តម្រូវឲ្យអនុវត្ត (១) នីតិវិធីចំណាយព្រម និង (២) នីតិវិធីតម្រូវឲ្យមានការស្នើសុំធានាចំណាយមុនបោះអាណត្តិទូទាត់

– ចំណាយតម្រូវឲ្យ អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ជាប្រភេទចំណាយ ដែលនីតិវិធីតម្រូវឲ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ មុនបោះផ្សាយអាណត្តិទូទាត់ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយក្រុមលទ្ធកម្មរបស់អង្គភាពថវិកាផ្ទាល់ ដោយត្រូវអនុលោមតាមប្រកាសលេខ២៤៩ សហវ ប្រក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា និងតាមការកំណត់កម្រិតទឹកប្រាក់ សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មជាធរមាន។

– ការទូទាត់ត្រូវបានអនុញ្ញាតក្រោយពេលទំនិញ សំណង់ និងសេវាត្រូវបានត្រួតពិនិត្យ វាយតម្លៃ ឬប្រគល់ទទួលជាស្កាពរ។ អង្គភាពថវិកាត្រូវចាត់ចែង និងកំណត់ចំនួនទឹកប្រាក់ចំណាយឲ្យបាន

[43] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ៥៨-៥៩

[44] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ៥៩

ច្បាស់លាស់ហើយត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ ទៅតាមចំនួនទឹកប្រាក់ពិតប្រាកដ ដែលត្រូវធ្វើការទូទាត់។

- ការធ្វើចលនាឥណទាន ឬនិយ័តកម្មឥណទានអាចអនុវត្តបានចាប់ត្រីមាសទី២ នៃឆ្នាំថវិកា ដោយអង្គភាពថវិកាត្រូវអនុលោមតាមនីតិវិធីដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកា កម្មវិធីត្រូវពន្យល់អំពីមូលហេតុឲ្យបានត្រឹមត្រូវច្បាស់លាស់ និងភាពចាំបាច់នៃការធ្វើចលនាឥណទាន ឬនិយ័តភាពឥណទាន និងត្រូវធានាថាការអនុវត្តនេះ មិនប៉ះពាល់ដល់លទ្ធផលដែលនឹងរួមចំណែកសម្រេចគោលបំណងនិងគោលនយោបាយរបស់ក្រសួង ស្ថាប័ន។

២.២.២ បន្ទុក និងធនធានហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់

កថាខណ្ឌទី២ ៖ ការចំណាយថវិការបស់អង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ៖

ក.សិទ្ធិអំណាច និង ការទទួលខុសត្រូវ

អង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ មានភារកិច្ច និង ការទទួលខុសត្រូវដូចខាងក្រោម៖[45]

១.ការរៀបចំថវិកា

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាពស្ថិតក្រោមឱវាទ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗនៃមាតិកាថវិកា។
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័នសាមី។
- ចូលរួមការចរចារថវិកាកម្រិតជំនាញ និង កម្រិតថ្នាក់ដឹកនាំតាមការអញ្ជើញរបស់អាណាប័កដើមខ្សែ ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[46]

២.ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួន ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំ ដែលបានវិភាជន៍ជូនដោយអាណាប័កដើមខ្សែ។
- រៀបចំគម្រោងចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាស រួចបញ្ជូនមកអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

[45] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ៥៩

[46] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ៥៩

២.៣ ការអនុវត្តថវិកាឃុំ សង្កាត់

ថវិកា ឃុំ សង្កាត់ អាចនឹងត្រូវបានកែតម្រូវក្នុងកំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច ឬហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ។

រតនាគារខេត្ត ក្រុង ត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់ និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម៖[47]

- ប្រមូល ឬទទួលចំណូលរបស់មេឃុំ សង្កាត់
- ទូទាត់ចំណាយ ដែលបានចេញអណត្តិដោយមេឃុំ ចៅសង្កាត់
- គ្រប់គ្រង និង បើកផ្តល់ថវិកា ឃុំ សង្កាត់
- រៀបចំរបាយការណ៍ គណនេយ្យហិរញ្ញវត្ថុ តាមកាលកំណត់។[48]

២.៣.១ កិច្ចប្រតិបត្តិការចំណូល និងចំណាយ

ក. កិច្ចប្រតិបត្តិការចំណូល

១. ចំណូលរបស់ឃុំ សង្កាត់ មាន ២ប្រភេទគឺ ៖ ចំណូលចរន្ត និងចំណូលមូលធន។

❖ **ចំណូលចរន្ត ចែកជា ៥ប្រភេទ៖**

- **ប្រភេទទី១**.ចំណូលពន្ធមូលដ្ឋាន
- **ប្រភេទទី២**.ចំណូលមិនមែនសារពើពន្ធ
- **ប្រភេទទី៣**.ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់ សម្រាប់រដ្ឋបាលទូទៅ
- **ប្រភេទទី៤**.ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ
- **ប្រភេទទី៥**.ចំណូលចរន្តផ្សេងៗ។

ខ.ចំណូលមូលធន

ចំណូលមូលធននេះ ចែកចេញជា ៤ប្រភេទ៖[49]

- **ប្រភេទទី១**.ចំណូលមូលធនបម្រុង ដូចមានចែងក្នុង មាត្រា ២២ នៃអនុក្រឹត្យនេះ
- **ប្រភេទទី២**.ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សម្រាប់អភិវឌ្ឍន៍មូលដ្ឋាន
- **ប្រភេទទី៣**.ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងតម្លៃគម្រោង
- **ប្រភេទទី៤**.ចំណូលមូលធនផ្សេងៗ។

[47] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៨

[48] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៨

[49] ទេព សុខ សៀវភៅហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ទំព័រ ២៨-២៩

គម្រោងថវិកា ឃុំ សង្កាត់ ត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការ កសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅ ក្រុមប្រឹក្សា ឃុំ សង្កាត់ពិនិត្យ និងអនុម័ត។ មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគម្រោងថវិកា ដែលបានអនុម័តរួច ទៅអភិបាលខេត្ត ក្រុង ឲ្យបានមុនថ្ងៃទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់។ គម្រោងថវិកា ត្រូវភ្ជាប់ជាមួយ នូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖[50]

- **របាយការណ៍សង្ខេបស្តីពី** មូលដ្ឋានក្នុងការរៀបចំ ចំណូល និងចំណាយ ព្រមទាំងកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការរៀបចំថវិកា។
- **របាយការណ៍ស្តីពី** ការអនុវត្តនៃឆ្នាំដំណើរការតារាងសង្ខេប នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ចាក់ក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ប្រសិនបើមាន។
- **កំណត់ហេតុស្តីពី** កិច្ចប្រជុំអនុម័តលើគម្រោង ថវិកា របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និង បញ្ជាក់ការទទួលស្គាល់លើគម្រោងថវិកា ឲ្យបានមុនថ្ងៃទី ៣០ ខែ វិច្ឆិកា។

  ការត្រួតពិនិត្យអនុលោមភាព ត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម ៖[51]

  ១. ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា។

  ២. តុល្យភាពថវិកា និងការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ។

  ៣. លក្ខខណ្ឌនៃការប្រើប្រាស់មូលនិធិ ឃុំ សង្កាត់ ដែលទទួលបាន។

  ៤. ការគ្រោងឥណទានថវិកា ទៅតាមគោលការណ៍ចំណាយចាំបាច់។

  ៥. តម្រូវការថវិកា វិនិយោគសម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ចាក់ច្បាស់លាស់ក្នុងផែនការរបស់ ឃុំ សង្កាត់។

អភិបាលខេត្ត ក្រុង មិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយ ដែលបានសម្រេចដោយ ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្រៅពីការពិនិត្យលើលក្ខខណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព។

[50] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៩

[51] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ៣០

និយាយរួម ឃុំ សង្កាត់មានប្រភពចំណូលពីរ៖[52]

- ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្តាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង កំរៃសេវាផ្សេងៗ
- ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ ចំណូលរដ្ឋសម្រាប់ថវិការបស់ខ្លួន
- ឃុំសង្កាត់មានសិទ្ធទទួលបាននូវប្រាក់កំរៃចំពោះការអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ណាមួយនៃរដ្ឋាភិបាលបានប្រគល់ឲ្យអនុវត្ត។ល។
- ចំណូលពីការចូលរួម ចំណែកបដិភាគពីប្រជាពលរដ្ឋ (បន្ថែមលើតម្លៃនៃគម្រោង)។

គ. អ្នកប្រតិបត្តិការចំណាយ

១. ចំណាយរបស់ឃុំ សង្កាត់មាន ២ប្រភេទ៖ ចំណាយចរន្ត និងចំណាយមូលធន។

❖ **ចំណាយចរន្ត ចែកជា ៧ប្រភេទគឺ៖**[53]

- **ប្រភេទទី១**.ចំណាយបៀវត្ស និង ប្រាក់បំណាច់
- **ប្រភេទទី២**. ចំណាយរដ្ឋបាលទូទៅ
- **ប្រភេទទី៣**.ចំណាយសេវាសាធារណៈ
- **ប្រភេទទី៤**.ចំណាយសម្រាប់មុខងារជាភ្នាក់ងារ
- **ប្រភេទទី៥**.ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច
- **ប្រភេទទី៦**.ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច
- **ប្រភេទទី៧**.ចំណាយមិនបានគ្រោងទុក។

❖ **ចំណាយមូលធន៖** ចែកចេញជា ២ប្រភេទ៖

- **ប្រភេទទី១**.ចំណាយវិនិយោគផ្នែករដ្ឋបាល
- **ប្រភេទទី២**.ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន។

[52] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ៣០

[53] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៩

២.៣.២. ការគ្រប់គ្រងថវិការដ្ឋបាលឃុំ សង្កាត់

២.៣.២.១.ប្រភពថវិកា ឃុំ សង្កាត់

ស្វ័យភាពថវិការដ្ឋបាល ឃុំ សង្កាត់ ត្រូវបានទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ដោយចាប់ផ្តើមពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ជាលើកដំបូងនៅឆ្នាំ២០០២ ក៏ដូចជា ការអនុវត្តគោលនយោបាយវិមជ្ឈការអំណាចនៅថ្នាក់មូលដ្ឋាន ដោយអនុញ្ញាតឲ្យរដ្ឋបាល ឃុំ សង្កាត់ ទទួលបានធនធាន ហិរញ្ញវត្ថុថវិកា និងទ្រព្យសម្បត្តិផ្ទាល់សម្រាប់ដំណើរការការងារនៅមូលដ្ឋាន។ រដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិទទួល ចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ និង កម្រៃសេវាផ្សេងៗ ពន្ធពីការជួល។ ពន្ធខាងលើនេះរាប់បញ្ចូលពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និងពីការជួល។ ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលឃុំ សង្កាត់ ការប្រមូលនេះត្រូវធ្វើក្នុងនាមជារដ្ឋបាល ឃុំ សង្កាត់ ។ រដ្ឋបាល ឃុំ សង្កាត់ ទទួលធនធានវិភាជន៍ពីចំណូលរដ្ឋ សម្រាប់ថវិការបស់ខ្លួន។

❖ **ធនធានវិភាជន៍នេះរួមមាន៖**[54]

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ។
- ទាយរជ្ជទាន និងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទាន ដែលបានមកពីប្រាក់ចំណូលរដ្ឋ។ ធនធានវិភាជន៍ ខាងលើនេះ គឺជាប្រាក់បន្ថែមពីលើចំណូលរបស់រដ្ឋបាល ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗ ដែលរដ្ឋបាលឃុំ សង្កាត់ ទទួលបានពីប្រាក់ចំណូលរដ្ឋ។

ក្នុងករណីការប្រគល់អំណាច មុខងាររបស់រាជរដ្ឋាភិបាល មានលក្ខណៈជាអចិន្ត្រៃយ៍ទៅឲ្យរដ្ឋបាល ឃុំ សង្កាត់ រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានធនធានហិរញ្ញវត្ថុ រយៈពេលយូរអង្វែងសម្រាប់ផ្តល់ឲ្យរដ្ឋបាលឃុំ សង្កាត់។

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាល ឃុំ សង្កាត់ និងនីតិវិធីដែលទាក់ទងនឹងការងារដូចខាងក្រោម៖[55]

- ថវិការដ្ឋបាលឃុំ សង្កាត់
- ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់ សម្រាប់រដ្ឋបាលឃុំ សង្កាត់
- ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់
- ទ្រព្យសម្បត្តិរដ្ឋបាលឃុំ សង្កាត់
- សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

[54] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៦

[55] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៦

ប្រភពនៃថវិកា ឃុំ សង្កាត់ បានកំណត់ក្នុងច្បាប់ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាបានផ្តល់សច្ចប័ន លើសេចក្តីព្រាងច្បាប់ស្តីពី " ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់" និងព្រឹទ្ធសភា បានយល់ព្រមលើគតិច្បាប់ទាំងស្រុងនាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០១ ច្បាប់នេះបានចូលជាធរមាន តាមព្រះរាជក្រមលេខ នស/រកម/ ០៣០១/០៥ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។ ច្បាប់នេះបានអនុញ្ញាតដល់ ឃុំ សង្កាត់ តាមរយៈមាត្រាមួយចំនួន ដូចខាងក្រោម៖[56]

- ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកា និង ទ្រព្យសម្បត្តិផ្ទាល់(មាត្រា ៧៣)។
- ឃុំ សង្កាត់ត្រូវរៀបចំ អនុម័តថវិកា របស់ខ្លួនជារៀងរាល់ឆ្នាំ(មាត្រា៧៩)។
- ឃុំ សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ខ្លួនដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកំរៃសេវា(មាត្រា៧៤)។
- ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវវិភាជន៍ ពីចំណូលរដ្ឋ សម្រាប់ថវិការបស់ខ្លួន(មាត្រា ៧៥)។
- ឃុំ សង្កាត់ មានសិទ្ធិទទួលប្រាក់កម្រៃ ចំពោះការអនុវត្តនូវ តួនាទី ជាភ្នាក់ងារតំណាងរដ្ឋ ដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយ នៃរាជរដ្ឋាភិបាលបានប្រគល់ឲ្យអនុវត្ត (មាត្រា ៧៦)។
- រដ្ឋបង្កើតឲ្យមានមូលនិធិឃុំ សង្កាត់(មាត្រា ៧៧)
- របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ (មាត្រា ៨៣)។

ឃុំ សង្កាត់ ត្រូវបង្កើតឲ្យមាននូវប្រព័ន្ធគ្រប់គ្រងតាមដាន និងត្រួតពិនិត្យ ហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន ៖[57]

- ✓ បទដ្ឋានហិរញ្ញវត្ថុ និងការអនុវត្តផ្នែកគណនេយ្យ
- ✓ ការចាត់ចែង គ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ
- ✓ តម្រូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ✓ ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុ ឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ លេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២។

[56] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ មាត្រា ៧៣-៧៤-៧៥-៧៦-៧៧-៧៩-៨៣ ឆ្នាំ ២០០១

[57] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៧

កថាខណ្ឌទី២. ការរៀបចំ និង អនុម័តថវិកា

ការរៀបចំថវិកាឃុំ សង្កាត់ មានប្រតិបត្តិការដូចខាងក្រោម៖[58]

- ថវិកាឃុំសង្កាត់ ទទួលខុសត្រូវរៀបចំគម្រោងថវិកា។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ អនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃ៣១ ខែតុលា។
- មេឃុំ សង្កាត់ ត្រូវបញ្ជូនគម្រោងថវិកា ដែលអនុម័តរួចទៅអភិបាលខេត្ត ក្រុងឲ្យបានមុនថ្ងៃទី១៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់។

[58] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤ ភ្នំពេញ ទំព័រ ២៧

ជំពូកទី៣

ការត្រួតពិនិត្យលើការអនុវត្តថវិកា

ឃុំ សង្កាត់

ជំពូកទី៣
ការត្រួតពិនិត្យលើការអនុវត្តថវិកាឃុំ សង្កាត់

៣.១. ការត្រួតពិនិត្យលើអាណាប័កដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាល់ការអនុវត្តចំណូល ចំណាយថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយគោរពទៅតាមមាតិកាថវិកា និង ប្លង់គណនេយ្យសាធារណៈ ហើយរាល់របាយការណ៍ចំណូល ចំណាយថវិការដ្ឋ និងរបាយការណ៍ហិរញ្ញវត្ថុត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈស្របតាមបទប្បញ្ញត្តិច្បាប់។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងរាល់កិច្ចប្រតិបត្តិហិរញ្ញវត្ថុ និង គណនេយ្យ តាមក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀតដែលបានអនុវត្តប្រតិបត្តិថវិការដ្ឋដើម្បីធានាការប្រមូលបាននូវព័ត៌មាន និងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកា។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ តាមរយៈអភិបាលហិរញ្ញវត្ថុអាចធ្វើការត្រួតពិនិត្យលើការចាយវាយក្នុងក្រសួងនីមួយៗ។ បើគ្មានទិដ្ឋាការបស់អភិបាលហិរញ្ញវត្ថុទេ ក្រសួងមិនអាចចាយវាយបានជាដាច់ខាត។ ដូចនេះ មុននឹងសម្រេចចំណាយអ្វីមួយ ក្រសួងត្រូវបញ្ជូនឯកសារទាំងអស់ទៅឱ្យអភិបាលហិរញ្ញវត្ថុពិនិត្យ និងផ្តល់ទិដ្ឋាការជាចាំបាច់។ អភិបាលហិរញ្ញវត្ថុនេះ ជាតំណាងរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុនៅក្នុងក្រសួងនីមួយៗ។ ចំណែកគណនេយ្យករវិញ មុខងាររបស់ខ្លួនគឺត្រូវពិនិត្យមើលឱ្យបានហ្មត់ចត់លើឯកសារចំណាយ ថាតើត្រឹមត្រូវតាមបែបបទច្បាប់ថវិកាឬទេមុននឹងបើកលុយឱ្យអ្នកផ្គត់ផ្គង់។ រីឯក្រុមអធិការហិរញ្ញវត្ថុភារៈកិច្ចសំខាន់ គឺត្រួតពិនិត្យជាទូទៅលើអណាប័កតូចៗ ដើម្បីឱ្យរដ្ឋមន្ត្រីហិរញ្ញវត្ថុ មានលទ្ធភាពយល់ដឹងលើសកម្មភាពរដ្ឋបាលទាំងមូល។[59]

៣.១.១ ការត្រួតពិនិត្យថវិកាដោយសភា

សភាមានសិទ្ធិត្រួតពិនិត្យលើការអនុវត្តថវិកា ហើយកិច្ចការនេះអាចបំពេញបានក្នុងពេលកំពុងអនុវត្ត ក៏ដូចជាក្រោយពេលអនុវត្តដែរ ។

៣.១.២.ការត្រួតពិនិត្យពេលកំពុងអនុវត្ត

កិច្ចការនេះ ត្រូវរាប់បញ្ចូលទៅក្នុងភារកិច្ចរបស់សភាក្នុងការតាមដាន និងត្រួតពិនិត្យ សកម្មភាពនៃរដ្ឋាភិបាល។ តាមធម្មតារដ្ឋាភិបាលមានកាតព្វកិច្ច ផ្តល់ជូនសភានូវរបាយការណ៍នានាស្តីអំពីការអនុវត្តន៍ថវិកា។

[59] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ បោះពុម្ព ភ្នំពេញ ទំព័រ ៦៥

រដ្ឋាភិបាលត្រូវរៀបចំចំលើយបំភ្លឺចំពោះសំណួរ ជាលាយលក្ខណ៍អក្សរ ឬដោយវាចារបស់សមាជិកសភា ដែលចង់ដឹងពីបញ្ហាអ្វីមួយយ។ ក្នុងករណីខ្លះសភាមាន សិទ្ធិបង្កើតគណៈកម្មាការ ពិសេសដើម្បីត្រួតពិនិត្យ ឆែកឆេរលើរឿងអ្វីមួយដែលគេយល់ថាសំខាន់។ ជាពិសេសក្នុងពេលពិភាក្សាជជែកគ្នាលើថវិកាប្រមូលម្តងៗ រដ្ឋាភិបាលត្រូវពន្យល់ និងជូនដំណឹងឱ្យបានច្បាស់លាស់ដល់សភា នូវស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងថវិកា។ សភាអាចសួរដេញដោលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុលើការអនុវត្តថវិកាមុននឹង អនុម័តលើថវិកាប្រចួន(ច្បាប់ហិរញ្ញវត្ថុកែតម្រូវ)។

ដើម្បីញុំាងឱ្យកិច្ចការត្រួតពិនិត្យកាន់តែមានភាពប្រសិទ្ធភាពខ្លាំងទៀត រដ្ឋសភាបារាំងបានសម្រេចបង្កើតកាលពីខែកុម្ភៈ ឆ្នាំ១៩៩៩ គណកម្មការពិសេសមួយហៅថា គណកម្មការវាយតម្លៃ និងត្រួតពិនិត្យ។ គណកម្មការនេះមានភារកិច្ចតាមដានពិនិត្យមើលលើប្រសិទ្ធភាពនៃចំណាយសាធារណៈ។ តាមការពិតរដ្ឋសភាបង្កើតគណកម្មការនេះគឺគ្រាន់តែមានគោលបំណងពង្រឹងភារកិច្ចតាមដានពិនិត្យមើលលើរដ្ឋាភិបាលតែប៉ុណ្ណោះ ហើយបើកិច្ចការនេះធ្វើទៅបានលទ្ធផលខ្លះ គេអាចឈានចូលទៅធ្វើវិសោធនកម្មលើបញ្ញត្តិបញ្ញាឆ្នាំ១៩៥៩បានខ្លះព្រោះច្បាប់ចុងក្រោយនេះបានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចច្រើនជាងសភា។[60]

៣.១.៣.ការត្រួតពិនិត្យពេលក្រោយអនុវត្ត

កាលណាថវិកាបានត្រូវអនុវត្តរួចហើយគេត្រូវរៀបចំធ្វើច្បាប់ទូទាត់ ដែលត្រូវអនុម័តដោយសភា។ ក្នុងច្បាប់ទូទាត់គេត្រូវបញ្ជាក់ឱ្យបានច្បាស់នូវចំណូល-ចំណាយពិតប្រាកដ។ គេអាចដឹងបានថា តើឱនភាពថវិកាមានកម្រិតដល់ណា? ហើយបើគេធ្វើការប្រៀបធៀបទៅនឹងគម្រោងមុន តើមានគម្លាតទំហំប៉ុនណា?

៣.២.ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុដោយសវនកម្មផ្ទៃក្នុង

ថវិកាទូទៅរបស់រដ្ឋត្រូវបានត្រួតពិនិត្យដោយ អគ្គសវនកម្មជាតិ។ អនុលោមតាម មាត្រា៧៩ នៃច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ប្រកាសឲ្យប្រើ ឆ្នាំ ២០០៨។[61] អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរដ្ឋាភិបាលជ្រាបជាព័ត៌មាន។ បណ្តាស្ថាប័នដែលគ្រប់គ្រង ដោយច្បាប់សវនកម្ម រួមមានបណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ ស្ថាប័នហិរញ្ញវត្ថុរដ្ឋចំណុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ ឬសេវាកម្មចំពោះរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គភាពផ្សេងទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុ

[60] ទេព សុខ ហិរញ្ញវត្ថុសាធាណៈ ឆ្នាំបោះពុម្ព២០២៤ បោះពុម្ព ភ្នំពេញ ទំព័រ ៦៧

[61] ទេព សុខ ហិរញ្ញវត្ថុសាធាណៈ ឆ្នាំបោះពុម្ព២០២៤ បោះពុម្ព ភ្នំពេញ ទំព័រ ៦៧

បន្ថែមលើទុនផ្គាល់ នៃឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទព្រមទាំងសម្បទានផ្សេងៗ ទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និង សហគ្រាសវិនិយោគ ឯកជន។[62]

៣.២.១.ប្រភេទនៃសវនកម្ម

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើ ៖[63]

១. សេចក្តីថ្លែងការណ៍ និង ធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រសួង ស្ថាប័ន ដែលមូលដ្ឋានសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុប របស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំ នៃការិបច្ឆេទ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនពេលដាក់ជូនអង្គនីតិប្បញ្ញត្តិ។

២. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងទៀត ដែលសំណូមពរដោយបណ្តាភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងបណ្តាឥណទាយក នៅក្នុងគម្រោងផ្តល់មូលនីធិក្រៅប្រទេស។ ការត្រួតពិនិត្យនេះត្រូវបញ្ជាក់អំពីភាពសមស្រប និងភាពត្រឹមត្រូវនៃឯកសារយុត្តិការណ៍ក្នុងការដកប្រាក និងការចំណាយលើគម្រោងនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុបង្ហាញនូវការសមស្របទៅនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន និងកិច្ចព្រមព្រៀងគម្រោង និងសវនកម្មលើការវាយតម្លៃចំពោះការសម្រេចគោលដៅនៅពេលចប់គម្រោងទាំងនេះ។

៣. ការអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមានរបស់សហគ្រាសវិនិយោគឯកជន ដែលបានទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាល ដើម្បីធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងកម្ពុជា។ សវនកម្មទាំងនេះសង្កត់ធ្ងន់លើការអនុវត្តទៅតាមកិច្ចព្រមព្រៀង និងបណ្តាលក្ខខណ្ឌនៃការអនុញ្ញាតពីរដ្ឋាភិបាល។

៤. តាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុ និង ធនាគារនៃរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួងនានា ឬ អាជ្ញាធរសម្រាប់ធ្វើការត្រួតពិនិត្យ ពិសេសឡើងវិញលើវិស័យមួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការរបស់ម្ចាស់សំណើរ។ ការអនុវត្តនៃសវនកម្ម ដែលមានចែងក្នុងមាត្រានេះ គឺស្ថិតនៅលើឆន្ទានុសិទ្ធិរបស់អគ្គសវនករ។

៥. សវនកម្មលើការគ្រប់គ្រង និងការប្រព្រឹត្តិទៅលើបណ្តាស្ថាប័នលើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ។ សវនកម្មរាប់បញ្ចូលទាំងលទ្ធកម្មសាធារណៈ បៀវត្សរ៍បុគ្គលិក កិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបេសកកម្ម៖[64]

- សវនកម្មលើការវាយតម្លៃអំពីការសន្សំសំចៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធភាពក្នុងការអនុវត្តទៅលើកម្មវិធីរបស់រដ្ឋាភិបាល។

[62] មាត្រា ២ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

[63] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ ភ្នំពេញ ទំព័រ ៦៨

[64] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ ភ្នំពេញ ទំព័រ ៦៨

- សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគម គណបក្សនយោបាយ និងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដែលទទួលជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលក្នុងទ្រង់ទ្រាយលើកលែងពន្ធគយ ពន្ធលើប្រាក់បៀវត្សរ៍ និងពន្ធអាករផ្សេងទៀតព្រមទាំងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលពុំមានការអនុញ្ញាតដោយច្បាប់។ គោលដៅនៃសវនកម្មនេះគឺដើម្បីកុំឲ្យរាជរដ្ឋាភិបាល ត្រូវបានបាត់បង់ប្រាក់ចំណូល ដែលបណ្តាលមកពីការ លើកលែងពន្ធ និងដើម្បីធានាថាស្ថាប័ន គ្រប់គ្រងបានដំណើរការទៅតាមក្របខណ្ឌនៃគោលបំណងរបស់ខ្លួន។

៣.២.២.ការអនុវត្តមុខងារសវនកម្មជាតិ

ដោយអនុលោមតាមច្បាប់ស្តីពី "សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០០" បានកំណត់ថា "អាជ្ញាធរសនវកម្មជាតិ មានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល និងអនុវត្តមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងបណ្តាសហគ្រាសសាធារណៈផងដែរ"។[65]

ក. ការអនុវត្តសវនកម្មផ្ទៃក្រៅ

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីគណនេយ្យ ប្រព័ន្ធគ្រប់គ្រង កិច្ចប្រតិបត្តិការ និង ការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងថវិកាដើម្បីផ្តល់ការធានា ឬទំនុកចិត្តថា ៖[66]

១. បណ្តាសកម្មភាពហិរញ្ញវត្ថុ និង សេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈ សេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍ ។

២. បណ្តាសកម្មភាពទាំងនេះ ត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ។

៣. ការត្រួតពិនិត្យនីតិវិធី និងការអនុវត្តដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យាកម្មវិធី និងលក្ខខណ្ឌ វិនិច្ឆ័យផ្សេងទៀត ដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រដ្ឋាភិបាល។

ខ.ប្រភេទសវនកម្មផ្ទៃក្រៅរបស់ឆ្លោតិបាល

ទន្ទឹមរដ្ឋាភិបាលធ្វើសវនកម្មផ្ទៃក្នុងទៅលើអង្គភាពរដ្ឋនានា គឺរដ្ឋបាលភិបាលនឹងធ្វើសវនកម្មផ្ទៃក្រៅផងដែរ សវនកម្មទាំងនោះរួមមាន៖[67]

១. សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

២. សវនកម្មលើការគ្រប់គ្រងកម្មវិធីគម្រោងឥណទាន ដែលបានមកពីមូលនិធិក្រៅប្រទេស។

[65] មាត្រា ១ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

[66] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ ទីកន្លែងបោះពុម្ព ភ្នំពេញ ទំព័រ ៦៨

[67] មាត្រា ២២ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

៣. សវនកម្មលើការគ្រប់គ្រង និង ការប្រព្រឹត្តទៅលើបណ្តាស្ថាប័ន។

៤. សវនកម្មលើការវាយតម្លៃ ការផ្តល់លទ្ធផលល្អ និង ប្រសិទ្ធភាពក្នុងការអនុវត្ត។

៥. សវនកម្មលើអង្គការដែលរកប្រាក់ចំណេញ និង សវនកម្មលើសហគ្រាសវិនិយោគឯកជន។

៦. សវនកម្មតាមសំណើពិសេស ។

គ.សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រដ្ឋាភិបាល

អគ្គសវនកម្មជាតិ អាចធ្វើសវនកម្មច្រើនប្រភេទដូចបានរៀបរាបខាងលើ តែនៅទីនេះលើកយកតែសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុមកសិក្សាបុណ្ណោះ មានដូចខាងក្រោម៖[68]

- សេចក្តីព្រាងច្បាប់ស្តីពី "ការទូទាត់ថវិការបស់រដ្ឋ" ។ ជាឯកសារហិរញ្ញវត្ថុសរុបរបស់រដ្ឋាភិបាល ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- អគ្គសវនករ ធ្វើសវនកម្មតែលើឯកសារទូទាត់ថវិកាទូទៅរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងជូនទៅរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន ហើយរបាយការណ៍នេះត្រូវចាត់ទុកថាជាឯកសារសាធារណៈ។
- ការធ្វើសវនកម្មលើសេចក្តីព្រាងច្បាបស្តីពីការទូទាត់ថវិការដ្ឋ៖ ជានិច្ចជាកាលរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗទៅរដ្ឋសភា ព្រឹទ្ធសភា ដើម្បីពិនិត្យ និងអនុម័ត។ ទន្ទឹមនឹងនេះរដ្ឋាភិបាលក៏ត្រូវបញ្ជូនឯកសារនេះទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើការត្រួតពិនិត្យដែរ។ អាជ្ញាធរសវនកម្មជាតិត្រូវធ្វើរបាយការណ៍ សវនកម្មបញ្ជាក់លើឯកសារនេះទៅរដ្ឋសភា និងព្រឹទ្ធសភា។ បើក្នុងរយៈពេល៩ខែ បន្ទាប់ពីបំណាច់ឆ្នាំ នៃការិយបរិច្ឆេទរាជរដ្ឋាភិបាលមិនបានផ្តល់ឯកសារស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំរបស់សវនកម្មជាតិទេអគ្គសវនករត្រូវធ្វើរបាយការណ៍ទៅរដ្ឋសភា និងព្រឹទ្ធសភាស្តីពីការខកខាននេះ ។ អគ្គសវនករ ត្រូវធ្វើការត្រួតពិនិត្យទៅលើរបាយការណ៍ របស់ស្ថាប័ននានានៃរដ្ឋាភិបាលលើកិច្ចការ ផ្សេងៗដូចជា៖[69]
  - អគ្គសវនករត្រូវរាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធ ក្នុងករណីដែលអង្គភាពណាមួយមានភាពមិនប្រក្រតីនៅក្នុង កិច្ចបញ្ជីការ គណនេយ្យ ការគ្រប់គ្រងរូបវត្ថុ និងទ្រព្យសកម្ម។

[68] មាត្រា ២៣ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

[69] មាត្រា ២៨ដល់២៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០

- អគ្គសវនករត្រូវរាយការណ៍ និងធ្វើកំណត់សំគាល់ជាទូទៅលើបណ្តាបញ្ហាដែលទាក់ទងដល់កិច្ចបញ្ជីការ គណនេយ្យ រូបិយវត្ថុ ទ្រព្យសកម្ម និងបំណុលអកម្មផ្សេងៗទៀត ដោយអនុឡោមតាម បទបញ្ញត្តិនៃច្បាប់ជាធរមាន។
- ទោះជាមានបទបញ្ញត្តិណាផ្សេងក៏ដោយ ដែលស្តីពីសវនកម្ម អគ្គសវនករធ្វើសវនកម្ម លើកិច្ចបញ្ជី គណនេយ្យ របស់អាជ្ញាធរ ឬស្ថាប័ននោះត្រូវផ្តល់លិខិតបញ្ជាក់និងរបាយការណ៍ផ្សេងៗទៀតដែលយល់ថាជាការចាំបាច់ចំពោះកិច្ចបញ្ជីការគណនេយ្យនោះ ទៅឲ្យអ្នកដឹកនាំអាជ្ញាធរ ឬស្ថាប័ននោះនិងទៅរដ្ឋសភា ព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធ។
- អគ្គសវនករត្រូវរាយការណ៍ជូនរដ្ឋសភា ព្រឹទ្ធសភា ជាប្រចាំនូវបញ្ហាទាំងឡាយណាដែលកើតចេញពីការបំពេញភារកិច្ច ឬប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចមានចែងក្នុងច្បាប់។
- ក្រោយពីមានការរៀបចំ របាយការណ៍ស្តីពីសវនកម្មនៃកិច្ចប្រតិបត្តិការរបស់អង្គភាព ណាមួយអគ្គសវនករត្រូវជូនច្បាប់ចម្លងបាយការណ៍នេះទៅប្រធានស្ថាប័នគ្រប់គ្រង។ ប្រសិនបើប្រធានស្ថាប័នគ្រប់គ្រងនោះត្រូវបានជូនយោបល់ជាលាយលក្ខណ៍អក្សរទៅអគ្គសវនករ ក្នុងកំឡុងពេល ២៨ថ្ងៃ អគ្គសវនករ ត្រូវពិចារណាលើយោបល់ទាំងនោះមុននឹងរៀបចំរបាយការណ៍ចុងក្រោយ។ ផ្ទុយទៅវិញ បើប្រធានស្ថាប័ននោះមិនឆ្លើយតបតាមការកំណត់ខាងលើ របាយការណ៍នោះត្រូវបានចាត់ទុកជាបានការ។

ឃ.សវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល

១. គោលការណ៍ទូទៅ

យោងតាមច្បាប់ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ចែងថា៖[70]

- រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្របស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែលនឹង ប្រធានអង្គភាពសាធារណៈ និងអភិបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការ រៀបចំក្របខណ្ឌនឹងគ្រប់គ្រងប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវស្របតាមបទដ្ឋានបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល។
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ច ទទួលខុសត្រូវណែនាំអំពី ការរៀបចំក្របខណ្ឌកិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង

[70] មាត្រា ៧២ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨

សហគ្រាសសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២. គោលបំណងនៃការបង្កើតសវនកម្មផ្ទៃក្នុង

ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា និងធ្វើសវនកម្មសារឡើងវិញ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើការសម្របសម្រួលការងារ ជាមួយអាជ្ញាធរសវនកម្មជាតិ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ គឺជាដំណើរការរបស់រាជរដ្ឋាភិបាលដែលធ្វើឡើង ដោយថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈដើម្បីផ្តល់នូវការធានាភាពសមស្របលើសមិទ្ធិកម្មនៃកម្មវត្ថុតាមបណ្តាផ្នែក ៖[71]

- ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ
- ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ
- ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ជា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្តន៍។

៣.ការបង្កើតសវនកម្មផ្ទៃក្នុង និង រចនាសម្ព័ន្ធ

- សវនកម្មផ្ទៃក្នុង ត្រូវបង្កើតឡើងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ។ មានរចនាសម្ព័ន្ធស្មើនឹងនាយកដ្ឋាន ចំណុះប្រធានស្ថាប័នហើយរាលសហគ្រាសសាធារណៈត្រូវបង្កើត សវនកម្មផ្ទៃក្នុង។
- ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយអនុក្រឹត្យ (អនុក្រឹត្យស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និង សហគ្រាស ឆ្នាំ ២០០៥)។ ដោយឡែកនៅមានក្រសួង ស្ថាប័ន មួយចំនួនពុំទាន់បានបង្កើតសវនកម្មផ្ទៃក្នុងរួមមាន៖ ព្រឹទ្ធសភា (២០១៤-២០១៨) ព្រះបរមរាជវាំង និងក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិ។

៤.តួនាទី និង ភារកិច្ចសវនកម្មផ្ទៃក្នុង

តួនាទីសវនកម្មផ្ទៃក្នុង គឺត្រូវវាយតំលៃដោយឯករាជ្យ នូវភាពសមស្រប គ្រប់គ្រាន់ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងនោះ និងផ្តល់នូវការធានាលើភាពគ្រប់គ្រាន់ នៃប្រព័ន្ធត្រួតពិនិត្យ ដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណង។ មានភារកិច្ច ធ្វើការវាយតំលៃដោយឯករាជ្យលើប្រសិទ្ធភាព ក្នុងការអនុវត្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ ក្រសួង ស្ថាប័ន និង សហគ្រាសសាធារណៈ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើ

[71] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ ទីកន្លែងបោះពុម្ព ភ្នំពេញ ទំព័រ ៧០

របាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវផ្ញើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិ ។

៥.មុខងារ និង ការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង

មុខងារ និង ការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង មានដូចខាងក្រោម៖[72]

១.ពិនិត្យឡើងវិញលើមុខងារ សកម្មភាពប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងកាលបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឲ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព។

២.កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អ លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែក គណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព។

៣.ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបានភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃ ព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រ ដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ។

៤. ពិនិត្យឡើងវិញលើប្រព័ន្ធ ដែលបានបង្កើតដើម្បីធានាបានទៅតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ បទបញ្ជា ទាំងឡាយដែលមានឥទ្ធិពលសំខាន់លើសេដ្ឋកិច្ច ប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណី ក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈអនុវត្តពុំបានសម្រេច ដូចបានរៀបរាប់ខាងលើចំបាច់សំណូមពរឲ្យមានការផ្លាស់ប្តូរថ្មី និងកែលំអ។

៥. ពិនិត្យឡើងវិញ លើការគ្រប់គ្រង ថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ ដែលមានឲ្យបានត្រឹមត្រូវ។

៦. វាយតំលៃភាពសន្សំសំចៃ ប្រសិទ្ធភាព លើការប្រើប្រាស់ ធនធាន និង កំណត់ការកែលំអ លើការអនុវត្តកិច្ចប្រតិបត្តិការព្រមទាំងការផ្តល់ជាអនុសាសន៍ ។

៧. ពិនិត្យឡើងវិញលើសេដ្ឋកិច្ចប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយមូលធន លើលទ្ធផលការងារ វិជ្ជមាន ឬអវិជ្ជមានតាមគោលបំណង គោលដៅ ដែលបានដាក់ចេញ និងតាមផែនការកំណត់។

[72] ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំបោះពុម្ព២០២៤ ទីកន្លែងបោះពុម្ព ភ្នំពេញ ទំព័រ ៧១

៨. ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រដើម្បីធានាឲ្យបាន៖

- តម្រូវការរបស់អ្នកប្រើប្រាស់ ត្រូវបានកំណត់ច្បាស់លាស់
- ការត្រួតពិនិត្យផ្ទៃក្នុងសមស្រប ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ការសាកល្បង នៃប្រព័ន្ធកុំព្យូទ័រ ត្រូវបានប្រព្រឹត្តទៅក្នុងដំហានសមស្រប
- ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រ ត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ។

៩. ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗ ក្រោយពេលតំឡើងរួច ដើម្បីកំណត់ប្រព័ន្ធ ទាំងនេះឆ្លើយតបតាម គោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងមានប្រសិទ្ធភាពខ្ពស់។

១០. ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាថាវិធានការបានដាក់ចេញ ក្នុងគោលបំណងការពារការកេងបន្លំ។ ប្រសិនការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា។

១១. ពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និង ការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពី ឥរិយាបទ និង ក្រមសីលធម៌ចំពោះមន្ត្រីរាជការ។

១២. សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឲ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា។

១៣. ធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ និង សេចក្តីសន្និដ្ឋាន នៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិស្តីពី៖

- សកម្មភាពកែលម្អ តាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង។
- សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និង បង្កើនភាពសន្សំសំចៃ មានប្រសិទ្ធភាព និងផ្តល់ផលល្អក្នុងកិច្ចប្រតិបត្តិការ។
- សវនកម្មផ្ទៃក្នុង ត្រូវធ្វើការសម្របសម្រួលការងារជាមួយ អាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាងការធ្វើសកម្មភាពស្ទួនគ្នា និងធ្វើសវនកម្មសារឡើងវិញ។
- ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្របច្បាស់លាស់គ្រប់គ្រាន់។
- ការរារាំងលើព័ត៌មាន និងបញ្ជី។

១៤. ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំត្រូវដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈពិនិត្យ និងសម្រេច។

១៥. វាយតម្លៃផែនការ ឬសកម្មភាពកែលំអលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង។ ប្រសិនបើ សកម្មភាពកែលំអនេះមិនមានលក្ខណៈសមស្របនោះទេត្រូវលើកយកមកពិភាក្សាបន្តដើម្បីឲ្យសម្រេចបានតាមសំណូមពរ ដែលអាចទទួលយកបាន ។

១៦. ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ ក្នុងការតាមដានសកម្មភាពកែលំអ លើអនុសាសន៍ ។

១៧. ប្រធានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់មាត់ជូនថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ឬក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ។

១៨. ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្មធ្វើ ជូនដល់ផ្នែកនីមួយៗ របស់ស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ ដែលទទួលបន្ទុកកែលំអតាមអនុសាសន៍។ សវនកម្មផ្ទៃក្នុងត្រូវបានបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ។

១៩. អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗដែលប្រធាន ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈប្រគល់ជូន។ ប្រធានស្ថាប័ន ក្រសួង នីមួយៗ ត្រូវសម្របសម្រួលបែងចែក ភារកិច្ចរវាងអាគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងនេះឲ្យសមស្រប។

៦. បេសកម្មវនកម្មផ្ទៃក្នុងសវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង នៅតាមបណ្តា ក្រសួង ស្ថាប័ន និង សហគ្រាសសាធារណៈត្រូវទទួលខុសត្រូវអនុវត្តមុខងារ ឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងវាយតម្លៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំ ស្ថាប័ន ក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សហគ្រាស។

ការធ្វើសវនកម្ម គឺមានគោលដៅ៖

- ជួយដល់ផ្នែកនីមួយៗនៃក្រសួង ស្ថាប័ន និង សហគ្រាសសាធារណៈខាងលើ ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។
- គោលដៅមួយទៀត គឺផ្តល់ឲ្យក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ នូវការវិភាគ ការវាយតម្លៃ អនុសាសន៍ មតិយោបល់ និងព័ត៌មាន ដែលទាក់ទងនឹងសកម្មភាពដែលបានត្រួតពិនិត្យ និងការពិនិត្យឡើងវិញ។

៧. ស្តង់ដារសវនកម្ម និង ក្រមសីលធម៌

ដើម្បីធ្វើឲ្យមុខងារសវនកម្មផ្ទៃក្នុង អនុវត្តមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញផ្សាយណែនាំលើស្តង់ដារ វិជ្ជាជីវៈ នៃសវនកម្មផ្ទៃក្នុង ក្រមសីលធម៌ ទំហំការងារ និងសិទ្ធិអំណាចនៃការគ្រប់គ្រងដែលត្រូវអនុវត្ត ដោយសវនកម្មផ្ទៃក្នុងដោយពិគ្រោះយោបល់ជាមួយអាជ្ញាធរសវនកម្មជាតិ ។

១.សមត្ថកិច្ចក្នុងការធ្វើសវនកម្មលើអាជ្ញាធរសវនកម្មជាតិ

ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនាមរដ្ឋសភា មានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញ នូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ។

ក្នុងករណីចាំបាច់យោងតាមសំណើរ របស់គណកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសម្រេចបង្កើតគណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ (យោងតាមច្បាប់បន្ថែម ទៅលើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០០)។

សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន

ក្រោយពីបានឆ្លងកាត់ការបកស្រាយទៅលើប្រធានបទខាងលើ និងការសិក្សាស្រាវជ្រាវទៅលើឯកសារជាច្រើនរួចមកដែលទាក់ទងទៅនឹងប្រធានបទស្តីពី "ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកាឃុំ សង្កាត់" យើងអាចសន្និដ្ឋានបានថា ដើម្បីឲ្យការអនុវត្តថវិកា ឃុំ សង្កាត់ ប្រព្រឹត្តទៅបានដោយរលូនស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាដំបូងមន្ត្រីរាជការដែលពាក់ព័ន្ធត្រូវបង្កើតក្រុមប្រឹក្សា ដោយមានរចនាសម្ព័ន្ធ និងមានផែនការច្បាស់លាស់នូវការប្រើប្រាស់ថវិកាឲ្យចំគោលដៅ។ ម្យ៉ាងទៀត គ្រប់មន្ត្រីទាំងអស់ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល ដោយគោរពទៅតាមលក្ខខណ្ឌច្បាប់ដែលមានជាធរមានបច្ចុប្បន្ន ដោយមិនចាំបាច់មានការភ័យខ្លាចក្នុងការអនុវត្ត ពោលគឺ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់កញ្ចប់ថវិកា ដែលទទួលបាននោះអភិវឌ្ឍន៍ឲ្យចំគម្រោង។ ជារៀងរាល់ឆ្នាំរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោង និងមានអំណះអំណាងច្បាស់លាស់ ដើម្បីទទួលបានកញ្ចប់ថវិកា ត្រៀមទុកឧបត្ថម្ភគាំទ្រ ដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឲ្យបានទាន់សភាពការ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ទាក់ទងទៅនឹងច្បាប់មេឃុំ ចៅសង្កាត់ ត្រូវស្មើសុំទៅតាមផែនការយុទ្ធសាស្ត្រ ថវិកាដែលមានចែងនៅក្នុងច្បាប់ ទន្ទឹមនឹងនោះរាល់ការអនុម័តលើគម្រោងអ្វីមួយ មេឃុំ ចៅសង្កាត់ត្រូវពិនិត្យឲ្យបានម៉ត់ចត់មិនត្រូវធ្វេសប្រហែស ខ្ជីខ្ជានាំឲ្យខាតថវិការដ្ឋ។ បើមានវិវាទកើតឡើងទាក់ទងទៅនឹងការអនុវត្តថវិកា គឺអាចជ្រើសរើសដំណោះស្រាយវិវាទតាមផ្លូវច្បាប់ ក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជារួមដើម្បីឲ្យការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិដោយស្របច្បាប់នៅកម្ពុជា គឺត្រូវគោរពទៅតាមដំណាក់កាលនីមួយៗ ដូចដែលយើងខ្ញុំធ្វើការបកស្រាយខាងលើ នោះមុននឹងមេឃុំ ចៅសង្កាត់មានបំណងសម្រេចចិត្ត អភិវឌ្ឍន៍នៅដែនសមត្ថកិច្ចរបស់ខ្លួនកន្លែងណាមួយ ត្រូវសិក្សាពីដំណាក់កាលនីមួយៗឲ្យបានច្បាស់លាស់ និងត្រៀមកញ្ចប់ថវិកាស្របទៅនឹងគម្រោងរបស់ខ្លួន ការធ្វើបែបនេះគឺធ្វើឲ្យមានភាពប្រសើរច្រើនដល់រដ្ឋាភិបាលរួមទាំងមេឃុំ ចៅសង្កាត់ ជៀសវាងការអភិវឌ្ឍន៍ខុសគោលដៅដែលនាំឲ្យមានវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ច។

យ៉ាងណាមិញបច្ចុប្បន្ននេះយើងសម្លឹងឃើញថា នៅតាមមូលដ្ឋានមួយចំនួនតូចមានការពុករលួយច្រើនដោយសារ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនមិនបានគោរពតាមគោលការណ៍ច្បាប់បានត្រឹមត្រូវនោះទេ ដោយធ្វើការកេងប្រវ័ញ្ចកញ្ចប់ថវិកាមួយចំនួនទុកក្នុងហោប៉ៅ ឬចែកបក្សពួករបស់ខ្លួន មិនបានរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធល្អ ពេលខ្លះមិនបានចុះត្រួតពិនិត្យឲ្យបានត្រឹមត្រូវធ្វើឲ្យម្ចាស់ការដ្ឋានកេងប្រវ័ញ្ចថវិកាក្នុងការសាងសង់យ៉ាងអាណាធិបតេយ្យ ជាហេតុនាំឲ្យប្រជាពលរដ្ឋជាច្រើនរងគ្រោះ និងលំបាកដោយសារការសាងសង់ខុសបច្ចេកទេស ផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗឆាប់ខូចខាត ងាយត្រឡប់ទៅជាសភាពដើមវិញ។

អនុសាសន៍

អនុសាសន៍

ដើម្បីឲ្យការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិមានលក្ខណៈល្អ និងមានទំនុកចិត្តជាងនេះទៅទៀត មុននឹងចេញលិខិតអនុញ្ញាតឲ្យធ្វើការអភិវឌ្ឍន៍ ឬធ្វើការសាងសង់សំណង់ នោះគប្បីអាជ្ញាធរមានសមត្ថកិច្ចចុះត្រួតពិនិត្យទីតាំង និងបញ្ជាក់ឲ្យកាន់តែច្បាស់ថាការសាងសង់នៅទីកន្លែងនោះពិតជាមានតម្រូវការចាំបាច់ពិតមែន ហើយចាំបន្តនីតិវិធីទៅដល់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ដើម្បីឲ្យកាន់តែលម្អិតអំពីផែនការក្នុងការរៀបចំ និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិព្រមទាំងវាយតម្លៃនូវគុណសម្បត្តិ ក៏ដូចជាគុណវិបត្តិផងដែរដើម្បីកុំឲ្យមានបញ្ហាជាយកថាហេតុ ដោយមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់គួរអនុវត្តផែនការឲ្យបានតឹងរឹងបំផុត។

មួយវិញទៀតយើងក៏ឃើញជាញឹកញាប់ផងដែរចំពោះមន្ត្រីមួយចំនួនតូចអាចនឹងមានការឆបោកថវិកាតាមរូបភាពផ្សេងៗ នោះដើម្បីលុបបំបាត់នូវរាល់ទង្វើទាំងនេះបាន ទាល់តែស្ថាប័នដែលពាក់ព័ន្ធទាំងអស់គួរចាត់វិធានការឲ្យបានហ្មត់ចត់បំផុត ដោយឲ្យមន្ត្រីជំនាញចុះត្រួតពិនិត្យបណ្តាគម្រោងក្នុងការរៀបចំ និងការអនុវត្តថវិកានៅកម្ពុជា។ បើពិនិត្យឃើញថា មានការក្លែងបន្លំណាមួយកើតឡើងគួរចាត់វិធានការអន្តរាគមន៍ និងបញ្ឈប់សកម្មភាពគម្រោងភ្លាមៗ ពីព្រោះវាជាកត្តាដែលបង្កឲ្យមានហានិភ័យចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន និងសូមផ្អាកការសាងសង់កុំឲ្យមានការសាងសង់បន្តទៅទៀត និងដាក់ទណ្ឌកម្មទៅតាមផ្លូវច្បាប់ឲ្យបានតឹងរឹងបំផុតចំពោះបុគ្គលដែលបានប្រព្រឹត្តខុស ធ្វើយ៉ាងណាកុំឲ្យមានមន្ត្រី ឬបុគ្គលដទៃហ៊ានធ្វើរឿងនេះបន្តទៀត ពោលគឺលុបបំបាត់ចេញឲ្យអស់នូវការរៀបចំ ការអនុវត្ត និងត្រួតពិនិត្យថវិកាឃុំ សង្កាត់ទាំងឡាយណាដែលមិនត្រឹមត្រូវតាមច្បាប់។ ជាងនេះទៀត ជាក់ស្តែងយើងឃើញថា ការបម្រើសេវាសាធារណៈនេះមានច្រើន ហើយក៏មានកន្លែងខ្លះបម្រើសេវាសាធារណៈបានល្អ រីឯកន្លែងខ្លះទៀតបម្រើសេវាសាធាណៈក៏មិនបានល្អជាច្រើនផងដែរ នេះក៏ដោយសារតែឥរិយាបថ និងសីលធម៌របស់មន្ត្រីមួយចំនួននៅមានកម្រិត និងពុំទាន់យកចិត្តទុកដាក់ឲ្យបានល្អិតល្អន់ក្នុងការបំពេញការងារ (ធ្វេសប្រហែស ខ្ជីខ្ជា ខ្ជិលច្រអូសមិនស្រលាញ់ការងារ) ជាមួយគ្នានេះដែររដ្ឋាភិបាល និងស្ថាប័នដែលពាក់ព័ន្ធទាំងអស់គួរមានដំណោះស្រាយលើរឿងនេះ ក៏ដូចជាជម្រុញដល់មន្ត្រីគ្រប់ថ្នាក់របស់ខ្លួនបញ្ជ្រាបនូវចំណេះដឹងសីលធម៌ ផ្តល់សេវាសាធារណៈឲ្យបានកាន់តែល្អ និងមានភាពរហ័សជាងមុនដោយមន្ត្រីរាជការទាំងអស់ត្រូវដឹងថាខ្លួន គឺជាឆ្អឹងខ្នងដែលមិនអាចខ្វះបានក្នុងការបន្តនិរន្តរភាពជាតិ។ ដូច្នេះការពង្រឹងសមត្ថភាពជាប្រចាំ និងចូលរួមក្នុងកិច្ចការធ្វើកំណែទម្រង់គឺជាកាតព្វកិច្ចចាំបាច់ដែលមិនអាចព្រងើយកន្តើយបាន។

មន្ត្រីសាធារណៈទាំងអស់ត្រូវចូលរួមអនុវត្ត និងគោរពតាម អភិក្រមការងារ សម្រាប់បំពេញបេសកកម្មជាសេនាធិការរបស់រាជរដ្ឋាភិបាលគឺ **ឆ្ពុះកញ្ជាក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់** ដែលជាប្រសាសន៍របស់សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តម ក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ បានដាក់ចេញដើម្បីបន្តកែទម្រង់ស្ថាប័ន លើកម្ពស់អធិការកិច្ចក្នុងវិស័យសាធារណៈ ឲ្យកាន់តែល្អប្រសើរ។

ឯកសារយោង

ឯកសារយោង

ក.បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១០
- កម្រងច្បាប់ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ១៩៩៥ ភ្នំពេញ
  - ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១១
- ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីសារពើពន្ធថ្មី ប្រកាសឲ្យប្រើលេខ នស/០៥២៣/ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣
- ច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឲ្យប្រើថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៣
- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២១

- **អនុក្រឹត្យ**

– អនុក្រឹត្យលេខ១២១ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩

– អនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹង ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

– អនុក្រឹត្យស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

- **ប្រកាស**

– ប្រកាសលេខ១៩៣៧ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យមុនប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

– ប្រកាសស្តីពី ការគ្រប់គ្រងបំណុលពន្ធដារ ខែវិច្ឆិកា ឆ្នាំ ២០២០

– ប្រកាសស្តីពី ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ខែសីហា ឆ្នាំ២០២០

- ប្រកាសស្តីពីសិទ្ធិអំណាច និងការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ឆ្នាំ២០១៦

ខ.សៀវភៅ

- សៀវភៅ បណ្ឌិត ទេព សុខ ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣ ភ្នំពេញ សៀវភៅសិក្សាគោល
- សៀវភៅ ហិរញ្ញវត្ថុសាធារណៈ ,រៀបរៀងដោយ បណ្ឌិត ទេព សុខ, ឆ្នាំ២០២៤
- សៀវភៅ ហិរញ្ញវត្ថុសាធារណៈ ,រៀបរៀងដោយ បណ្ឌិត ទេព សុខ, ឆ្នាំ២០២២-២០២៣
- សៀវភៅ ហិរញ្ញវត្ថុសាធារណៈ ,រៀបរៀងដោយ សាស្ត្រាចារ្យ ឡាញ់ ដា, ឆ្នាំ២០២៣
- សៀវភៅ ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ,រៀបរៀងដោយ ឯកឧត្តម អ៊ុំ សារឹទ្ធ ឯកឧត្តម ប៊ុន រុទ្ធា និង លោក គឹម សុចិត្រា, ឆ្នាំ២០២១

គ.ប្រព័ន្ធផ្សព្វផ្សាយ និង គេហទំព័រ

YouTube: https://youtu.be/Q1MFUrBQ8Mc?si=JHYXnnpsBVb0cXaM ចូលមើលថ្ងៃទី៦ឧសភា២០២៤

Facebook: https://t.me/ddceveryday ចូលមើលថ្ងៃទី២០ឧសភា២០២៤

ឧបសម្ព័ន្ធ

បញ្ជីឧបសម្ព័ន្ធ

បញ្ជីឧបសម្ព័ន្ធ១៖ សំណុំឯកសារទាក់ទងនឹងការស្នើសុំថវិកា ឃុំ សង្កាត់

បញ្ជីឧបសម្ព័ន្ធ២៖ សំណុំឯកសារទាក់ទងនឹងការប្រើប្រាស់ថវិកា ឃុំ សង្កាត់

បញ្ជីឧបសម្ព័ន្ធ៣៖ សំណុំឯកសារចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ការត្រៀបត្រងឆ្នាំ២០២៤

បញ្ជីឧបសម្ព័ន្ធ១

សំណុំឯកសារទាក់ទងនឹងការស្នើសុំថវិកា ឃុំ សង្កាត់

ឧទាហរណ៍ : សេចក្តីសំរេច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត មណ្ឌលគីរី
ស្រុក ពេជ្រាដា
ឃុំ ប៊ូស្រា
លេខ :.....ស.ស.រ

សេចក្តីសំរេច
ស្តីពី
ការបង្កើតគណៈកម្មាធិការកសាងផែនការ និងឥទិកាឃុំប៊ូស្រា

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតូនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។
- យោងប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រ.ក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។
- យោងប្រកាសណែនាំលេខ ៣៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាឃុំ ប៊ូស្រា ថ្ងៃទី .....ខែ .....ឆ្នាំ ..... ។

សំ រ េ ច

ប្រការ ១ ..

បង្កើតគណៈកម្មាធិការកសាងផែនការ និង ថវិកា ឃុំ ប៊ូស្រា ដែលមានសមាសភាព ដូចខាងក្រោម ÷

១. លោក ....(តូនាទី)..... ជាប្រធាន
២. លោកស្រី..... .....(តូនាទី)..... ជាសមាជិក
៣. លោក..... .....(តូនាទី)..... ជាសមាជិក
៤. លោក..... .....(តូនាទី)..... ជាសមាជិក
៥. . . . ។ល។

ប្រការ ២ ..

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ មានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

- ជួយមេឃុំក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ
- ត្រូវអនុវត្តវិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងតំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
- ជួយមេឃុំក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ ។

ប្រការ ... ..

.....

.....។

ប្រការ ... ..

.....

.....។

ប្រការ ... ..

ត្រូវចាត់ទុកជានិភាករណ៍ នូវ.....(បើមាន) ។

ប្រការ ... ..

សមាសភាពដែលមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី..... ខែ..... ឆ្នាំ.....

មេឃុំ

<u>ចម្លងជូន</u>

(ហត្ថលេខា និងត្រា)

- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកពេជ្រាដា

(ឈ្មោះ)

"ដើម្បីជូនជ្រាប"

- ដូចមានចែងក្នុងប្រការ១

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ

បញ្ជីឧបសម្ព័ន្ធ២

សំណុំឯកសារទាក់ទងនឹងការប្រើប្រាស់ថវិកា ឃុំ សង្កាត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទំរង់គំរូលេខ ១.៦ "ក"
(ទិដ្ឋាការធ្វើដំណើរ)

ខេត្ត ក្រុង :.....
ស្រុក ខណ្ឌ :.....
ឃុំ សង្កាត់ :.....

ទិដ្ឋាការធ្វើដំណើរ

យោងលិខិតបញ្ជាបេសកកម្ម : លេខ..... ចុះថ្ងៃទី.....ខែ..... ឆ្នាំ.....
ផ្តល់អោយលោក លោកស្រី :..... មុខងារ.....
ទៅបំពេញបេសកកម្មនៅ :.....
ចាប់ពីថ្ងៃទី :..... ដល់ថ្ងៃទី.....

កន្លែងចេញដំណើរ និងមកដល់	ថ្ងៃ ខែ ឆ្នាំ	មធ្យោបាយធ្វើដំណើរ	សេចក្តីបញ្ជាក់របស់អង្គភាព ហត្ថលេខា និងត្រា
ចេញដំណើរពី.....			
កន្លែងមកដល់.....			
ចេញដំណើរពី.....			
កន្លែងមកដល់.....			

ភាគរាយការណ៍សុំទូទាត់របស់អ្នកទៅបំពេញបេសកកម្ម

- ឧបត្ថម្ភថ្លៃធ្វើដំណើរ :.....
- ឧបត្ថម្ភប្រចាំថ្ងៃ :.....

សរុប :.....

ថ្ងៃទី..... ខែ..... ឆ្នាំ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

មេឃុំ ចៅសង្កាត់ **បេឡាករបុរេប្រទាន** **អ្នករាយការណ៍**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទំរង់តំរូលេខ ១.៣ "ខ"
(លិខិតស្នើ)

ខេត្ត ក្រុង :.....
ស្រុក ខណ្ឌ :.....
ឃុំ សង្កាត់ :.....
លេខ :.....ល.ស

ថ្ងៃទី.... ខែ..... ឆ្នាំ.....

គោរពជូន
ឯកឧត្តម អតិបាលខេត្ត.....

កម្មវត្ថុ : សំណើសុំកាត់ប្រាក់ឧបត្ថម្ភរបស់លោក.....ជាសមាជិកក្រុមប្រឹក្សាឃុំ។

យោង : - មាត្រា៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បទបញ្ជាផ្ទៃក្នុងរបស់ឃុំ
- ស្មារតីអង្គប្រជុំក្រុមប្រឹក្សាឃុំ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ (នាងខ្ញុំ) មានកិត្តិយស សូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា លោក.....(**ដាក់ឈ្មោះ**).....ដែលជាសមាជិកក្រុមប្រឹក្សាឃុំ..... មិនបានបំពេញ តួនាទីរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នោះទេ ។ ជាក់ស្តែង.....(**រៀបរាប់អំពីកំហុស ដែលសមាជិកក្រុមប្រឹក្សាឃុំរូបនោះ បានប្រព្រឹត្តកន្លងមក**)..... ។ ម្យ៉ាងទៀត ទោះបីជា ក្រុមប្រឹក្សាឃុំ បានប្រជុំស្តីបន្ទោស និងណែនាំហើយក៏ដោយ ក៏សមាជិកក្រុមប្រឹក្សារូបនេះ នៅតែមិនព្រមកែខ្លួនដដែល ។

ក្រុមប្រឹក្សាឃុំ បានសំរេចថា នឹងកាត់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់លោក.....ចំនួន០២ខែ គឺខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០០៤ តាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាឃុំ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ ដើម្បីយកប្រាក់នេះទុកជាប្រយោជន៍ថវិកាឃុំ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាពិនិត្យ និងសំរេចដោយសេចក្តីអនុគ្រោះ ។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ (នាងខ្ញុំ) ។

(សូមជូនភ្ជាប់ជាមួយនូវ កំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំ ចំនួន០១ច្បាប់)

មេឃុំ ចៅសង្កាត់

(ហត្ថលេខា និងត្រា)

(ឈ្មោះ)

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- សាលាស្រុក .....
- រតនាគារខេត្ត .....
- .....

"ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

បញ្ជីឧបសម្ព័ន្ធ៣ៈ

សំណុំឯកសារចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមត្រួតឆ្នាំ២០២៤

ថវិកាសង្ខេប ឆ្នាំ២០២៣-២០២៤

ថវិកាថ្នាក់ក្រោមជាតិ (ឯកតាលានរៀល)	២០២៣		២០២៤		% កំណើន
	ច្បាប់	% ធ.ស.ស.	គ្រោង	% ធ.ស.ស.	
ចំណូលសរុបថវិកាថ្នាក់ក្រោមជាតិ	**2.602.507**	**1,99%**	**2.612.960**	**1,83%**	**0,4%**
ចំណូលសារពើពន្ធ	2.172.350	1,66%	2.214.721	1,55%	2,0%
ចំណូលមិនមែនសារពើពន្ធ	430.157	0,33%	253.413	0,18%	-41,1%
ចំណូលផ្សេងៗ	-	-	144.826	0,10%	-
ចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ	**4.061.797**	**3,11%**	**4.331.871**	**3,03%**	**6,6%**
ចំណាយចរន្ត	3.548.797	2,71%	3.796.871	2,66%	7,0%
ចំណាយមូលធន	513.000	0,39%	535.000	0,37%	4,3%
ឱនភាពថវិកា	**-1.459.290**	**-1,12%**	**-1.718.911**	**-1,20%**	**17,8%**
ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ	**1.459.290**	**1,12%**	**1.718.911**	**1,20%**	**17,8%**
រាជធានី-ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ)	14.226	0,01%	15.170	0,01%	6,6%
ក្រុង-ស្រុក	470.141	0,36%	553.342	0,39%	17,7%
ឃុំ-សង្កាត់	753.350	0,58%	894.755	0,63%	18,8%
មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់	221.573	0,17%	255.644	0,18%	15,4%

ច្បាប់
ស្តីពី
ហិរញ្ញវត្ថុសម្រាប់
ការគ្រប់គ្រងឆ្នាំ២០២៤

ជំពូកទី១

ថវិកាថ្នាក់ជាតិ

មាត្រា១ ..

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ តាមមាតិកាថវិកា និងតាមក្រសួង ស្ថាប័ន ដូចមានចែងក្នុងតារាង ១ ដែលភ្ជាប់មកជាមួយច្បាប់នេះ: ក្នុងទឹកប្រាក់សរុបចំនួន២៩ ៨៩៥ ៩៨០លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលសារពើពន្ធ.....២៥ ៧៥៩ ០៦១លានរៀល
- ចំណូលមិនមែនសារពើពន្ធ.....៣ ០៧៧ ៤១៦លានរៀល
- ចំណូលផ្សេងៗ.....១ ០៥៩ ៥០៣លានរៀល។

មាត្រា២ ..

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវបានកំណត់ស្មើនឹង៣៤ ៤៩៧ ៤៤៤លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត..... ២៣ ៨០៥ ៨៣៨លានរៀល
- ចំណាយមូលធន..... ១០ ៦៩១ ៦០៦លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

.....៤ ៤៨៣ ៧៣០លានរៀល

- ដោយថវិកាថ្នាក់ជាតិ.....៣ ៧៥៣ ៥២០លានរៀល
  + គម្រោងវិនិយោគផ្ទាល់.....២ ៩៨៧ ៧៥១លានរៀល
  + បដិភាគវិនិយោគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
  ..... ៧៦៥ ៧៦៩លានរៀល
- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
  ..... ៧៣០ ២១០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

.....៦ ២០៧ ៨៧៦លានរៀល។

មាត្រា៣ .-

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកា ដូចមានចែងក្នុងមាត្រា២នៃច្បាប់នេះ ត្រូវបានបែងចែកតាមក្រសួង និងស្ថាប័ននីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង ៣ និងតារាង ៦ ដែលភ្ជាប់មកជាមួយច្បាប់នេះ។

មាត្រា៤ .-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា.....១០ ៦៩១ ៦០៦លានរៀល
- ឥណទានទូទាត់.....១០ ៦៩១ ៦០៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. ថវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា.....៤ ៤៨៣ ៧៣០លានរៀល
- ឥណទានទូទាត់.....៤ ៤៨៣ ៧៣០លានរៀល

ខ. ថវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា.....៦ ២០៧ ៨៧៦លានរៀល
- ឥណទានទូទាត់.....៦ ២០៧ ៨៧៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនិងស្ថាប័ននីមួយៗដូចមានចែងក្នុងតារាង ៤ ដែលភ្ជាប់មកជាមួយច្បាប់នេះ។

មាត្រា៥ .-

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ រវាងស្ថានភាពចំណូលនិងចំណាយថវិកាដែលត្រូវបានរៀបចំនៅក្នុងតារាង ១ ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង ៣ ស្តីពីចំណាយថវិកាថ្នាក់ជាតិ មានបង្ហាញនៅក្នុងតារាង ៨ ភ្ជាប់មកជាមួយច្បាប់នេះ ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- ចំណូលថវិកាថ្នាក់ជាតិសរុប.....២៩ ៨៩៥ ៩៨០លានរៀល
- ចំណាយថវិកាថ្នាក់ជាតិសរុប..... ៣៨ ៨៩៧ ៨៨៤លានរៀល
  - ចំណាយចរន្ត.....២៣ ៨០៥ ៨៣៨លានរៀល
  - ចំណាយមូលធន..... ១០ ៦៩១ ៦០៦លានរៀល

- អតិរេកនៃថវិកាចរន្ត..... (+)៥ ០៣០ ៦៣៩លានរៀល
- សមតុល្យធនធាន និងបន្ទុកថវិកា (ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ)

  ..... (-)៤ ៦០១ ៤៦៤លានរៀល
- តម្រូវការហិរញ្ញប្បទាន.....(+)៦ ៧១៦ ១៤៩លានរៀល
  - ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ..... (+)៤ ៦០១ ៤៦៤លានរៀល
  - ការទូទាត់ប្រាក់ខ្ចី..... (+)២ ១១៤ ៦៨៥លានរៀល
- ប្រភពហិរញ្ញប្បទាន.....(+)៦ ៧១៦ ១៤៩លានរៀល
  - ហិរញ្ញប្បទានក្រៅប្រទេស..... (+)៦ ២៧៦ ១៤៩លានរៀល
  - ហិរញ្ញប្បទានក្នុងប្រទេស.....(+)៤៤០ ០០០លានរៀល
    + បោះផ្សាយមូលបត្រដ្ឋ..... (+)៤៤០ ០០០លានរៀល។

ជំពូកទី២

ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋ

មាត្រា៦ .–

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ៧០០ ០០០ ០០០SDR(មួយប៊ីលានប្រាំពីរយលានអេសដេអ៊ែ)។

ការខ្ចីប្រាក់ពីគេដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទាន ដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចីប្រាក់ពីគេ សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ និងគាំទ្រមូលនិធិទ្រទ្រង់ថវិកា ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីប្រាក់ពីគេនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង។

មាត្រា៧ .–

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលបោះផ្សាយលក់មូលបត្រដ្ឋក្នុងកម្រិត៤៤០ ០០០លានរៀល សម្រាប់សងប្រាក់ដើមនិងការប្រាក់នៃមូលបត្រដ្ឋ

ដែលបានចោះផ្សាយនាថ្ងៃកន្លងមក និងសម្រាប់ធ្វើហិរញ្ញប្បទានលើគម្រោងវិនិយោគដែលអាចផ្តល់ចំណូលត្រង់មករាជរដ្ឋាភិបាលនិងផ្តល់ផលរហ័ស ដើម្បីជានាបាននូវប្រសិទ្ធភាពនៃការវិនិយោគនិងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈនិងថវិកាជាតិ។

មាត្រា៨ .-

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលឱ្យរដ្ឋាករទឹកស្វយ័តសៀមរាបខ្ចីនូវទឹកប្រាក់ចំនួន៣៨ ៤៤០លានរៀល សម្រាប់អនុវត្តគម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាបឆ្នាំ២០២៤-២០២៦។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃការឱ្យប្រាក់គេខ្ចីនេះ។

មាត្រា៩ .-

មិនអនុញ្ញាតឱ្យក្រសួងឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្រយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ឬបង្កើតកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀតដល់រាជរដ្ឋាភិបាល ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

ជំពូកទី៣

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា១០ .-

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១០៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ និងបទប្បញ្ញត្តិនៃមាត្រា៣៥និងមាត្រា៥៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ សរុបចំនួន៦ ៩៦៩ ១៥៨,៣លានរៀល ត្រូវបានកំណត់ដូចខាងក្រោម ៖

ក. ថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ចំណូលថវិកាសរុប.....៣ ៥៦៣ ៨៧៤,៨លានរៀល

- ចំណូលសារពើពន្ធ.....២ ២១៤ ៧២១លានរៀល
- ចំណូលមិនមែនសារពើពន្ធ.....២៣៨ ៥៧៩លានរៀល
- ចំណូលផ្សេងៗ.....១ ១១០ ១៧៤,៨លានរៀល

ដែលក្នុងនោះមាន ៖

- ឧបត្ថម្ភធនពីថ្នាក់ជាតិ.....៩៨៥ ៦៨៩,២លានរៀល
  + ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត
    .....១៥ ១៧០លានរៀល
  + ការប្រគល់មុខងារអប់រំ..... ៨៣ ៥០៩,២លានរៀល
  + ការប្រគល់មុខងារសុខាភិបាល..... ៨៨៧ ០១០លានរៀល
- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ..... ១២៨ ៤៨៥,៦លានរៀល។

ចំណាយថវិកាសរុប.....៣ ៥៦៣ ៨៧៤,៨លានរៀល

- ចំណាយចរន្ត.....៣ ០២៨ ៨៧៤,៨លានរៀល
- ចំណាយមូលធន..... ៥៣៥ ០០០លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង ២ និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ និងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង ៧ ដែលភ្ជាប់មកជាមួយច្បាប់នេះ។

ខ. ថវិការបស់រដ្ឋបាលក្រុង ស្រុក

ចំណូលថវិកាសរុប.....២ ២៥៥ ២៨៤,៥លានរៀល

- ចំណូលមិនមែនសារពើពន្ធ..... ១៤ ៨៣៤លានរៀល
- ចំណូលផ្សេងៗ.....២ ២៤០ ៤៥០,៥លានរៀល

ដែលក្នុងនោះមាន ៖

- ឧបត្ថម្ភធនពីថ្នាក់ជាតិ.....២ ២២០ ១១០,៥លានរៀល
  + ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក..... ៥៥៣ ៣៤២លានរៀល
  + ការប្រគល់មុខងារអប់រំ..... ១ ៦៦៦ ៧៦៨,៥លានរៀល
- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ.....២០ ៣៤០លានរៀល។

ចំណាយថវិកាសរុប..... ២ ២៥៥ ២៨៤,៥លានរៀល

ចំណាយចរន្ត.....២ ២៥៥ ២៨៤,៥លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ. ថវិការបស់រដ្ឋបាលឃុំ សង្កាត់

ចំណូលថវិកាសរុប.....១ ១៥០ ៣៩៩លានរៀល

- ឧបត្ថម្ភពីថ្នាក់ជាតិ.....១ ១៥០ ៣៩៩លានរៀល
  - ចំណូលសង្កាត់ចំណុះរាជធានី..... ៦២ ៤៧៨លានរៀល
  - ចំណូលសង្កាត់ចំណុះក្រុង..... ១១២ ០៥៨លានរៀល
  - ចំណូលឃុំ.....៩៧៥ ៨៦៣លានរៀល។

ចំណាយថវិកាសរុប.....១ ១៥០ ៣៩៩លានរៀល

- ចំណាយចរន្តសរុប.....១ ១៥០ ៣៩៩លានរៀល
  - ចំណាយសង្កាត់ចំណុះរាជធានី.....៦២ ៤៧៨លានរៀល
  - ចំណាយសង្កាត់ចំណុះក្រុង.....១១២ ០៥៨លានរៀល
  - ចំណាយឃុំ.....៩៧៥ ៨៦៣លានរៀល។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្នែកក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៤

ពិតានចំនួនបុគ្គលិកស៊ីវិល

មាត្រា១១ .-

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ចំនួនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ ត្រូវបានកំណត់ស្មើនឹង១៥៨ ៤៧៩នាក់ ដូចមានចែងក្នុងតារាង **៥.១** ដែលភ្ជាប់មកជាមួយច្បាប់នេះ។

មាត្រា១២ .-

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ចំនួនសមាជិកក្រុមប្រឹក្សា មន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកូមិ និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ស្មើនឹង១៩២ ៨២៥នាក់ ដូចមានចែងក្នុងតារាង **៥.២** ដែលភ្ជាប់មកជាមួយច្បាប់នេះ។

ជំពូកទី៥

អវសានប្បញ្ញត្តិ

មាត្រា១៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៤ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែ ក្ញ ឆ្នាំ២០២៣

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន